# គំរោងសាកល្បងស្តីពីសិទ្ធិស្ត្រី ក្នុងភាពជាម្ចាស់សហគមន៍
# ស្រុកអង្គស្នួល ខេត្តកណ្តាល
# ខែធ្នូ ឆ្នាំ២០០៥-ខែកក្កដា ឆ្នាំ២០០៧

---

## របាយការណ៍សកម្មភាពរបស់ការិយាល័យសិទ្ធិស្ត្រីនៃអង្គការលីកាដូ
## ខែកញ្ញា ឆ្នាំ២០០៧

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា នឹងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និង ស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

**លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៧ របស់ខ្លួន ដូចខាងក្រោមៈ**

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យដែលរក្សាចងក្រងសំណុំរឿងទៅក្នុងទិន្នន័យដើម្បីងាយស្រួលក្នុងការរកឯកសារនឹងវិភាគឱ្យបានឆាប់រហ័ស។
- **ការិយាល័យអប់រំសិទ្ធិមនុស្ស** គឺជាការិយាល័យដែលបើកវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមគោលដៅនានាដូចជា មន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ ព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស នឹងជួយជនរងគ្រោះនានាក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិក ដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយឱ្យពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្រ្តដល់ពិរុទ្ធជន ទណ្ឌិត និង មន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្រ្តនឹងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណកម្ម** ជាការិយាល័យផ្តល់សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណកម្ម នឹងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើទារុណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា នឹងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្រ្តី** ជាការិយាល័យអប់រំសិទ្ធិស្រ្តីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្រ្តី នឹងធ្វើការតស៊ូមតិ ដើម្បីឱ្យមានការផ្លាស់ប្តូរផ្នែកច្បាប់ និង សង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង:**

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១

ទូរសារ: (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល: contact@licadho.org

គេហទំព័រ: http://www.licadho.org/

# មាតិកា


**សេចក្ដីថ្លែងអំណរគុណ** ~~~~~~~~ **ក**

**១. សេចក្ដីផ្ដើម** ~~~~~~~~ **១**

**២. ជនបង្គោល** ~~~~~~~~ **៣**

ជនបង្គោលជាក់លាក់ -------- ៣

ជនបង្គោល -------- ៣

រដ្ឋអំណាចមូលដ្ឋាន -------- ៥

**៣. គំរោងសាកល្បង** ~~~~~~~~ **៦**

វគ្គបណ្ដុះបណ្ដាលដល់ជនបង្គោល -------- ៦

វគ្គបណ្ដុះបណ្ដាលសំរាប់មន្ត្រីមូលដ្ឋាន -------- ៧

ឧបករណ៍អប់រំ -------- ៨

យុទ្ធនាការតស៊ូមតិ -------- ៨

សកម្មភាពក្នុងសហគមន៍ -------- ៩

វេទិកាសហគមន៍ -------- ១០

**៤. ការវាយតំលៃ** ~~~~~~~~ **១១**

ដែនកំណត់នៃការវាយតំលៃ -------- ១២

**៥. លទ្ធផលសំរេច** ~~~~~~~~ **១៣**

លទ្ធផលសំរេច -------- ១៣

**ឧបសម្ព័ន្ធទី១: សាច់រឿងល្ខោនសំរាប់សំដែងក្នុងឱកាសវេទិកាសហគមន៍** ~~~~~~~~ **១៤**

**ឧបសម្ព័ន្ធទី២: លទ្ធផលនៃការវាយតំលៃ** ~~~~~~~~ **២១**

លទ្ធផលនៃការវាយតំលៃលើមន្ត្រីមូលដ្ឋាន (ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧) ---------- ២៨

លទ្ធផលនៃការវាយតំលៃលើសមាជិកសហគមន៍ (ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧) ------ ២៧

សេចក្តីសន្និដ្ឋានរួមលើការវាយតំលៃ ---------------------------------- ៣១

**ឧបសម្ព័ន្ធទី៣៖ ទំរង់វាយតម្លៃជនបង្គោល** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៣

**ឧបសម្ព័ន្ធទី៤៖ ទំរង់វាយតម្លៃអាជ្ញាធរមូលដ្ឋាន** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~ ៣៤

**ឧបសម្ព័ន្ធទី៥៖ ទំរង់វាយតម្លៃសហគមន៍** ~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~៣៩

□□□

# សេចក្តីថ្លែងអំណរគុណ


សូមថ្លែងអំណរគុណដល់គ្រូបង្រៀនផ្នែកសេវាសង្គម មកពីសាកលវិទ្យាល័យ Quebec ក្នុងទីក្រុង Montreal (UQAM) ជាពិសេសចំពោះ Nancy Guberman Annie Gusew និង Elizabeth Harper ដែលបានផ្តល់ការគាំទ្រ និងអនុសាសន៍ដ៏មានតំលៃលើគំរោងសាកល្បងរហូតមក។

ម្យ៉ាងវិញទៀត សូមថ្លែងអំណរគុណដល់ជនបង្គោល អាជ្ញាធរដែនដី និង សមាជិកសហគមន៍នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ដែលបានអនុញ្ញាតិឱ្យយើងធ្វើការជាមួយសហគមន៍អស់រយះពេលជាង១ឆ្នាំ ក្នុងគោលបំណងកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍ទាំងនោះ។

សូមថ្លែងអំណរគុណចំពោះការផ្តល់ជំនួយថវិការសំរាប់គំរោងសាកល្បង ពីសំណាក់រដ្ឋាភិបាលកាណាដា តាមរយះទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា (CIDA)។

Agence canadienne de développement international
Canadian International Development Agency


□□□

# ១. សេចក្តីផ្តើម

ឆ្លងកាត់តាមប្រវត្តិសាស្ត្រកន្លងមក ប្រជាជនខ្មែរបានទទួលរងនូវទុក្ខវេទនានៃវប្បធម៌ហិង្សាមួយដែលបានបន្សល់ពីរបបខ្មែរក្រហម និង ក្រុមអ្នកនយោបាយជាច្រើន។ អំពើហិង្សានេះបានបន្តជះឥទ្ធិពលមកលើប្រជាជនខ្មែរជាច្រើន ដែលមានស្ត្រីជាក្រុមមួយដែលងាយរងគ្រោះបំផុត។ អំពើហិង្សាលើស្ត្រី ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និង ករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ ជាបញ្ហារំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា។

កន្លងមកដោយសារការឆ្លើយតប និង ការអន្តរាគមន៍របស់រដ្ឋាភិបាលទាក់ទងនឹងការរំលោភសិទ្ធិស្ត្រីនៅមានកំរិត ហេតុដូច្នេះបានជាការទទួលខុសត្រូវទាំងនេះភាគច្រើនធ្លាក់លើសង្គមស៊ីវិល ដែលត្រូវជួយនឹងអប់រំស្ត្រី អាជ្ញាធរមូលដ្ឋាន អ្នកប្រព្រឹត្តអំពើហិង្សា នឹងដល់សាធារណៈជនទូទៅ។ ការិយាល័យសិទ្ធិស្ត្រីរបស់អង្គការលីកាដូធ្វើការឃ្លាំមើល នឹងស៊ើបអង្កេតលើអំពើហិង្សាចំពោះស្ត្រី អប់រំជនបង្គោល អ្នកតាក់តែងច្បាប់ និង សាធារណជនទូទៅស្តីអំពីអំពើហិង្សាចំពោះស្ត្រី។ ការិយាល័យសិទ្ធិស្ត្រីក៏ធ្វើការតស៊ូមតិ តាងនាមឱ្យអង្គការលីកាដូ និង ក្នុងនាមជាសមាជិកនៃសម្ព័ន្ធភាពស្ត្រី ដើម្បីផ្លាស់ប្តូរច្បាប់ដែលរើសអើងចំពោះស្ត្រី និង ដើម្បីអនុម័ត នឹងអនុវត្តច្បាប់ការពារសិទ្ធិស្ត្រីក្នុងព្រះរាជាណាចក្រកម្ពុជា។

*គំរោងសាកល្បងអំពីសិទ្ធិស្ត្រីក្នុងភាពជាម្ចាស់សហគមន៍* ត្រូវបានបង្កើតឡើងក្នុងគោលបំណងបង្កើននូវចំណាត់ការបែបចូលរួមចំពោះបញ្ហារំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ និង ការជួញដូរផ្លូវភេទ ដោយបង្កើនភាពជាម្ចាស់ដល់ស្ត្រីក្នុងការបង្កើតក្រុមសកម្មភាពតស៊ូមតិ ដែលផ្តល់អំណាចដ៏មានប្រសិទ្ធិភាពដល់ស្ត្រី ដើម្បីការពារនឹងជួយគ្នាទៅវិញទៅមកនៅក្នុងសហគមន៍របស់ខ្លួន។ គំរោងសាកល្បងនេះក៏មានគោលបំណងបង្កើនសមត្ថភាព និង ភាពទទួលខុសត្រូវដល់មន្ត្រីថ្នាក់ស្រុក អាជ្ញាធរដែនដី ដើម្បីចំណាត់ការចំពោះករណីជាក់លាក់នៃការរំលោភបំពានសិទ្ធិស្ត្រី។ គំរោងសាកល្បងនេះ ក៏មានសក្តានុពលក្នុងការជះឥទ្ធិពលលើទស្សនៈ ទំនុកចិត្ត និង អត្តចរិតរបស់ស្ត្រី និង បុរសផងដែរក្នុងរូបភាពជាក់ស្តែង និង និរន្តរភាព។

ការិយាល័យសិទ្ធិស្ត្រីរបស់អង្គការលីកាដូ (ភ្នំពេញ) បានបង្កើត ហើយបានអនុវត្តគំរោងសាកល្បងនេះក្នុងភូមិចំនួន៨ នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល ចាប់តាំងពីខែធ្នូ ឆ្នាំ២០០៥ ដល់ ខែឧសភា ឆ្នាំ២០០៧។ គំរោងនេះត្រូវបានបង្កើតឡើងដើម្បីបង្កើនសិទ្ធិស្ត្រីក្នុងភាពជាម្ចាស់ ដោយផ្តល់នូវចំណេះដឹង យុទ្ធសាស្ត្រ និង ធនធាន

អនុវត្តជាក់ស្តែងដល់ស្ត្រីក្នុងសហគមន៍ ដើម្បីឱ្យពួកគេអាចទប់ស្កាត់ នឹងកាត់បន្ថយករណីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និង ករណីជួញដូរផ្លូវភេទ។ គំរោងសាកល្បងមានគោលបំណងជាពិសេសក្នុងការៈ

១. បង្កើនការយល់ដឹងអំពីករណីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរផ្លូវភេទ ក្នុងរង្វង់សហគមន៍បង្គោល ដោយពន្យល់ផ្ទាល់នូវវិធានការណ៍ជាក់ស្តែងដែលអាចទប់ស្កាត់ករណីទាំងនោះមិនឱ្យកើតឡើង និង ដើម្បីការពារជនរងគ្រោះ។

២. បង្កើនសមត្ថភាព ទំនុកចិត្ត និង ភាពជាម្ចាស់ដល់ស្ត្រីជនបង្គោល ក្នុងសហគមន៍នីមួយៗ ដើម្បីឱ្យគាត់ចេះធ្វើការតស៊ូមតិប្រកបដោយប្រសិទ្ធិភាព ដើម្បីទទួលបានសិទ្ធិការពារពីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និង ករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ។

៣. បង្កើនសមត្ថភាព និង ភាពទទួលខុសត្រូវដល់មន្ត្រីថ្នាក់ស្រុក អាជ្ញាធរមូលដ្ឋាន ដើម្បីឱ្យគាត់យល់ដឹង នឹងមានចំណាត់ការចំពោះករណីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរផ្លូវភេទ ដោយបង្ហាញនូវការយកចិត្តទុកដាក់ ការអាណិតអាសូរដល់ជនរងគ្រោះ ព្រមទាំងការអនុវត្តន៍ច្បាប់ដែលមានសព្វថ្ងៃ។

□□□

# ២. ជនបង្គោល

បន្ទាប់ពីធ្វើការស្ទាបស្ទង់ជាមូលដ្ឋាននៅខែធ្នូ ឆ្នាំ២០០៥រួចមក គំរោងសាកល្បងបានសំរេចជ្រើសរើសយកឃុំ និង ភូមិនៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល មកធ្វើជាតំបន់បង្គោល ដូចមានខាងក្រោម:

**ឃុំឪឡោក**

ភូមិត្រពាំងអារក្ស និង ភូមិបឹងគ្រើល

**ឃុំសំរោងលើ**

ភូមិគីរីថ្មី ភូមិមង្គលបូរី និង ភូមិស្វាយឧត្តម

**ឃុំពន្សាំង**

ភូមិត្រពាំងអារក្ស និង ភូមិទួល

តំបន់បង្គោលខាងលើនេះ ត្រូវបានជ្រើសរើសដោយផ្អែកលើលទ្ធផលនៃការស្ទាបស្ទង់ជាមូលដ្ឋាន។ តាមការស្ទាបស្ទង់ជាមូលដ្ឋានបានបង្ហាញថា ភូមិខាងលើមានអំពើហិង្សាកើតឡើងខ្ពស់បំផុត។ ម្យ៉ាងវិញទៀត ភូមិដែលត្រូវបានជ្រើសរើសទាំងអស់នេះមានចំនួនប្រជាពលរដ្ឋរស់នៅច្រើនជាងគេ។ អាជ្ញាធរក្នុងតំបន់នេះមានសេចក្តីសោមនស្សរីករាយក្នុងការចូលរួមចំណែកក្នុងគំរោងសាកល្បងនេះផងដែរ។

## ជនបង្គោលជាគោលដៅ

### ជនបង្គោល

ស្ត្រីនៅក្នុងសហគមន៍ "ជនបង្គោល" ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងគំរោងជាពីរដំណាក់កាល។ ជាបឋមអង្គការលីកាដូបានរៀបចំផ្សព្វផ្សាយដោយពន្យល់អំពីតួនាទីរបស់ជនបង្គោល ហើយក៏បានបញ្ចូលនូវលក្ខខណ្ឌជ្រើសរើសមួយចំនួនដែលមានដូចខាងក្រោម:

១. ជាស្ត្រី

២. អាយុ ពី ២០-៤០ឆ្នាំ

៣. ចេះអាន និងសរសេរ

៤. ចិត្តទូលាយ នឹងស្ម័គ្រចិត្តក្នុងការចែករំលែកចំណេះដឹង និង បទពិសោធន៍ដល់អ្នករស់នៅក្នុងសហគមន៍ ដើម្បីប្រឆាំង នឹងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ

៥. ចេះសហការគ្នាល្អ នឹងចេះធ្វើការជាក្រុម

៦. មានប្រជាប្រិយភាពក្នុងចំណោមអ្នកនៅក្នុងសហគមន៍

៧. អាចចំណាយពេល ដើម្បីចូលរួមសកម្មភាពមួយចំនួនដូចជា: វគ្គបណ្តុះបណ្តាលរយៈពេល២ថ្ងៃ អង្គប្រជុំប្រចាំខែ វេទិកាសហគមន៍ និង សកម្មភាពផ្សេងៗទៀត ប្រសិនបើមានតំរូវការចាំបាច់ពីបុគ្គលិកគំរោងរបស់អង្គការលីកាដូ

បន្ទាប់មកអង្គការលីកាដូ បានប្រកាសជូនដំណឹងដល់មេឃុំ និង មេភូមិ ដោយមានការផ្តល់អនុសាសន៍ពីសំណាក់អាជ្ញាធរដែនដីក្នុងការជ្រើសរើសជនបង្គោលសំរាប់គំរោង។ យើងបានអញ្ជើញស្ត្រីចំនួន ៤៨នាក់ (៦នាក់មកពីភូមិនីមួយៗ) ដើម្បីធ្វើជាជនបង្គោលនៅក្នុងគំរោងសាកល្បង ប៉ុន្តែ មានស្ត្រីតែចំនួន ៣៩នាក់ប៉ុណ្ណោះ ដែលគំរោងទទួលយក ហើយបានចូលរួមវគ្គបណ្តុះបណ្តាល និង វគ្គតាមដានសំខាន់ៗ។

ជនបង្គោលទាំងអស់ជាស្ត្រីដែលមានអាយុពី ២៤-៥០ឆ្នាំ។ ក្នុងចំណោមនោះមានស្ត្រី ៣នាក់ដែលមិនបានចូលរៀន នឹងមិនចេះអក្សរ។ ជនបង្គោលភាគច្រើនជាមនុស្សវណ្ណៈកណ្តាលនៅក្នុងភូមិ។

ជាលទ្ធផល ដែលអនុញ្ញាតឱ្យអាជ្ញាធរមូលដ្ឋានដែលសុទ្ធសឹងជាសមាជិកគណៈបក្សប្រជាជនកម្ពុជា ធ្វើការជ្រើសរើសជនបង្គោល មន្ត្រីទាំងអស់នោះបានជ្រើសរើសស្ត្រី ដែលសុទ្ធសឹងជាសមាជិករបស់គណៈបក្សប្រជាជនឱ្យចូលរួម។ ជនបង្គោលដែលបានជ្រើសរើសពុំមានលក្ខណៈលាយចំរុះគ្នាគ្រប់គ្រាន់នោះទេ ហើយយើងពិបាកក្នុងការនិយាយថា តើអ្នកដែលត្រូវបានជ្រើសរើសនោះ ជាអ្នកតំណាងឱ្យស្ត្រីក្នុងសហគមន៍ដ៏ធំរបស់ពួកគេឬក៏អត់។


អាជ្ញាធរដែនដីធ្វើការរួមគ្នាក្នុងវគ្គបណ្តុះបណ្តាល

## រដ្ឋអំណាចមូលដ្ឋាន

អាជ្ញាធរដែនដីត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគំរោងសាកល្បងនេះ។ មានមន្ត្រីមូលដ្ឋាន ២៥នាក់ មកពីភូមិទាំង៨ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងគំរោងសាកល្បងនេះ ប៉ុន្តែ មានមន្ត្រីចំនួន ២៣នាក់ប៉ុណ្ណោះ បានទទួលការអញ្ជើញ ហើយយល់ព្រមចូលរួមវគ្គបណ្តុះបណ្តាល។

**មន្ត្រីមូលដ្ឋានជ្រើសរើសចូលរួម**

| តួនាទី | ចំនួន | បុរស | ស្រី |
|---|---|---|---|
| មេភូមិ | ៨ | ៨ | |
| មេឃុំ | ៣ | ៣ | |
| ប៉ូលីសឃុំ | ៦ | ៦ | |
| ប៉ូលីសស្រុក | ២ | ២ | |
| តំណាងអភិបាលស្រុក | ១ | | ១ |
| ជំទប់ឃុំ | ៣ | ៣ | |
| **សរុប** | ២៣ | ២២ | ១ |

□□□

# ៣. គំរោងសាកល្បង

បន្ទាប់ពីបានជ្រើសរើសជនបង្គោល និង អាជ្ញាធរដែនដី អង្គការលីកាដូបានបើកវគ្គបណ្តុះបណ្តាលដល់ជនបង្គោលដែលបានជ្រើសរើសលើប្រធានបទផ្សេងៗគ្នា។ វគ្គបណ្តុះបណ្តាលនីមួយៗត្រូវបានចូលរួមដោយអ្នកសំរបសំរួល២នាក់ ព្រមទាំងបុគ្គលិកម្នាក់ផ្តល់ជំនួយផ្នែករដ្ឋបាល និង ភ័ស្តុភារផងដែរ។

## វគ្គបណ្តុះបណ្តាលដល់ជនបង្គោល

អង្គការលីកាដូបានបើកវគ្គបណ្តុះបណ្តាលជាបឋមដែលមានរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១៧ ដល់ ១៨ ខែសីហា ២០០៦។ ប្រធានបទក្នុងវគ្គបណ្តុះបណ្តាលលើកទី១នេះ លើកឡើងអំពីសិទ្ធិស្ត្រីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការប្រព្រឹត្តិអំពើហិង្សាលើស្ត្រី (ជាពិសេសអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ) និងច្បាប់នានាដែលពាក់ព័ន្ធនឹងបញ្ហាទាំងនេះ។ វគ្គហ្វឹកហ្វឺនបានប្រើនូវវិធានការជាក់ស្តែង ការសំដែងឈុតខ្លីៗ ( Role-play ) និងវិធីសាស្ត្រចូលរួមដល់ស្ត្រីដែលជាអ្នកចូលរួមផងដែរ។ ដោយស្ត្រីមួយចំនួនពុំសូវចេះអក្សរ វគ្គបណ្តុះបណ្តាលនេះមិនផ្តោតលើឯកសារទ្រឹស្តីទេ។

អង្គការលីកាដូបានបើកវគ្គបណ្តុះបណ្តាលលើកទី២ ដែលមានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី ៤ ដល់ទី ៦



ខែតុលា ឆ្នាំ២០០៦។ ដោយសារតែតំរូវការបញ្ចប់លើមេរៀន ទើបវគ្គនេះត្រូវធ្វើឡើងរហូតដល់៣ថ្ងៃ។ ប្រធានបទក្នុងវគ្គទី២នេះលើកឡើងពីទំនាក់ទំនងដោយផ្ទាល់ និងវិធីសាស្ត្រអនុវត្តជាក់ស្តែង ចំពោះការលើកកំពស់ការយល់ដឹងស្តីពីការឃ្លាំមើលសហគមន៏ និងការបង្កើតក្រុមតស៊ូមតិ លើករណីរំលោភសិទ្ធិស្ត្រីជាអាទិភាព ក្នុងសហគមន៏នៃជនបង្គោល។ វគ្គហ្វឹកហ្វឺននោះ ក៏បានប្រើនូវវិធានការជាក់ស្តែង ការសំដែងឈុតខ្លីៗ (Role-play) និងវិធីសាស្ត្រចូលរួមដូចក្នុងវគ្គបណ្តុះបណ្តាលលើកទី១ដែរ។

វគ្គតាមដានដែលមានរយៈពេល១ថ្ងៃ ចំនួន៦លើក ត្រូវបានធ្វើឡើងតាមកាលបរិច្ឆេទដូចខាងក្រោមៈ

- ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០០៦
- ថ្ងៃទី ៤ ខែមករា ឆ្នាំ២០០៧
- ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០០៧
- ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧
- ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧
- ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៧

វគ្គទាំងនេះមានគោលបំណងតាមដានលើចំងល់ ឬ បញ្ហានានា ពង្រឹងនូវខ្លឹមសារដែលបានបង្ហាត់បង្ហាញក្នុងវគ្គបណ្តុះបណ្តាលលើកទី១ នឹងផ្តល់ជាជំនួយដល់ជនបង្គោលក្នុងសហគមន៍របស់ខ្លួន ក្នុងការលើកកំពស់ការយល់ដឹង ការឃ្លាំមើលសហគមន៍ និង សកម្មភាពការងារក្រុមតស៊ូមតិចំពោះករណីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និង ករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ។

ការវាយតំលៃត្រូវបានធ្វើឡើងបីលើក ចំពោះជនបង្គោលម្នាក់ៗ និងការប្រមូលមតិយោបល់ដែលបានលើកឡើងដាក់ជូនអង្គការលីកាដូ។

វេទិកាសហគមន៍ត្រូវបានធ្វើឡើងក្នុង ខែកក្កដា ឆ្នាំ២០០៧ ដើម្បីបង្ហាញនូវរបកគំហើញពីរបាយការណ៍នេះ។ ជនបង្គោលទាំងអស់ត្រូវបានអញ្ជើញឱ្យចូលរួម ដើម្បីបញ្ចេញយោបល់។

## វគ្គបណ្តុះបណ្តាលសំរាប់មន្ត្រីមូលដ្ឋាន

អង្គការលីកាដូបានបើកវគ្គបណ្តុះបណ្តាលជាបឋមដែលមានរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី៣១ ដល់ទី១ ខែកញ្ញា ឆ្នាំ២០០៦។ ប្រធានបទក្នុងវគ្គបណ្តុះបណ្តាលនេះ ផ្តោតលើការយល់ដឹងជាក់ស្តែង និងអំពីនិយមន័យរបស់ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ និងច្បាប់ដែលពាក់ព័ន្ធនានា។ វគ្គហ្វឹកហ្វឺនទាំងនេះ បានប្រើនូវវិធានការជាក់ស្តែង ការសំដែង (Role-plays) និងវិធីសាស្ត្រចូលរួមផងដែរ។

អង្គការលីកាដូបានបើកវគ្គបណ្តុះបណ្តាលលើកទី២ដែលមានរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៦ ដល់ទី២៨ ខែតុលា ឆ្នាំ២០០៧ ដែលវគ្គបណ្តុះបណ្តាលនេះផ្តោតលើឥទ្ធិពលចិត្តសាស្ត្រ-សង្គម អំពើហិង្សាលើជនរងគ្រោះ និងវិធានការជាក់ស្តែងដើម្បីឆ្លើយតបនឹងបញ្ហាពាក់ព័ន្ធនានា និងកិច្ចការពារសិទ្ធិជនរងគ្រោះតាមក្របខ័ណ្ឌច្បាប់។

នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួមត្រូវបានស្នើសុំឱ្យសំដែងនូវការប្តេជ្ញាចំពោះសាធារណជន ក្នុងការលើកកំពស់និងការពារសិទ្ធិស្ត្រីដោយស្របច្បាប់ នឹងអនុវត្តដំណើរការទាំងឡាយដែលបានព្រមព្រៀងគ្នាក្នុងវគ្គបណ្តុះបណ្តាល។ ប៉ុន្តែ អ្នកចូលរួមមិនបានបំពេញនូវសំណើរនោះជាលាយលក្ខណ៍អក្សរទេ។

ការវាយតំលៃត្រូវបានធ្វើឡើងជាមួយមន្ត្រីមូលដ្ឋាននៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧ ដោយបានផ្តល់មតិយោបល់ដល់អង្គការលីកាដូផងដែរ។

វេទិកាសហគមន៍ត្រូវបានធ្វើឡើងក្នុងខែកក្កដា ឆ្នាំ២០០៧ ដើម្បីបង្ហាញនូវការយល់ឃើញនៃរបាយការណ៍នេះ។ មន្ត្រីមូលដ្ឋានទាំងអស់ដែលបានចូលរួមវគ្គបណ្តុះបណ្តាល ត្រូវបានអញ្ជើញចូលរួមដើម្បីបញ្ចេញយោបល់ក្នុងវេទិកាសហគមន៍នោះផងដែរ។

## ឧបករណ៍អប់រំ

អង្គការលីកាដូបានបង្កើតជាផ្ទាំងរូបភាព ដែលបង្ហាញពីទិដ្ឋភាពនៃករណីអំពើហិង្សា ហើយដាក់ក្បែរផ្ទាំងរូបភាព ដែលបង្ហាញពីទិដ្ឋភាពគ្រួសារដែលរស់នៅដោយសន្តិភាព ហើយបានដាក់ស៊ុម ប្រមទាំងចែកជូនផ្ទាំងរូបភាពទាំងនោះដល់ជនបង្គោល និងមន្ត្រីមូលដ្ឋានទាំងអស់ ហើយបានប្រគល់ផ្ទាំងរូបភាពចំនួន១០០ ដល់ជនបង្គោល ដើម្បីចែកចាយដល់អ្នកដែលរស់នៅក្នុងសហគមន៍ផងដែរ។

អង្គការលីកាដូបានបោះពុម្ព *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ* ជាសៀវភៅណែនាំ និងបានបែងចែកសៀវភៅណែនាំនោះ ចំនួន ១.០០០ក្បាលដល់ជនបង្គោលសហគមន៍ និង មន្ត្រីមូលដ្ឋាន។

## យុទ្ធនាការតស៊ូមតិ

ជនបង្គោលបានចូលរួមក្នុងយុទ្ធការ ១៦ថ្ងៃរបស់គណៈកម្មាធិការកម្ពុជាដើម្បីស្ត្រី CAMBOW[9] ដើម្បីប្រឆាំងនឹងអំពើហិង្សាដោយសារយេនឌ័រ (យុទ្ធនាការរយៈពេល១៦ថ្ងៃ) ចាប់ពីថ្ងៃទី២៥ វិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៦ ដោយបានចែកប្រតិទិនចំនួន ៨០០ផ្ទាំងដោយមានពាក្យជាសារខ្លីស្តីពីការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ជួយរៀបចំបញ្ចាំងវីដេអូក្នុងស្រុកអង្គស្នួល ដោយរាប់បញ្ចូលទាំងឈុតឆាកអប់រំស្តីពីអំពើហិង្សាក្នុងគ្រួសារ និងខ្លឹម

---

[9] គណៈកម្មាធិការកម្ពុជាដើម្បីស្ត្រី ជាសហភាគីរវាងអង្គការក្រៅរដ្ឋាភិបាលចំនួន៣៦ ដែលធ្វើការដើម្បីបង្កើន បុព្វហេតុស្ត្រីខ្មែរ ដោយផ្តោតជាពិសេសលើករណីអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ និងការជួញដូរស្ត្រី ដើម្បីគោលបំណងអាជីវកម្មផ្លូវភេទ។ បច្ចុប្បន្ននេះអង្គការលីកាដូជាប្រធានគណៈកម្មាធិការកម្ពុជាដើម្បីស្ត្រីនេះ។

សារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងច្បាប់ថ្មី ដោយបំផុសការយល់ដឹងនៅក្នុងសហគមន៍ ដោយមានអ្នកចូលរួមចំនួន ៣០០នាក់។

ជនបង្គោលជាច្រើននាក់បានចូលរួមប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិ ៨ មិនា ២០០៧ ដោយបានថតយកនូវឥទ្ធិពលនៃអំពើហិង្សាក្នុងគ្រួសារដែលស្តែងចេញពីឃុតឆាកសំដែងមកផ្សារភ្ជាប់នឹងឆាកជីវិតរស់នៅរបស់ខ្លួន និងធ្វើការផ្លាស់ប្តូរទង្វើទាំងនោះតាមលទ្ធភាពដែលអាចធ្វើបាន។ នាថ្ងៃ ៨ ខែមិនា ឆ្នាំ២០០៧ ក៏បានផ្សព្វផ្សាយកម្មវិធីវិទ្យុចំនួន ១៤ដង តាមរយៈស្ថានីយ៍វិទ្យុចំនួន៣ លើកម្មវិធីផ្សេងៗគ្នាផងដែរ។ ជនបង្គោលទាំងអស់ក៏បានចូលរួមក្នុងសកម្មភាពនៅមណ្ឌលអប់រំកែប្រែទី២ (CC2) ពន្ធនាគារតាខ្មៅ និង ពន្ធនាគារប៉ូលីសយុត្តិធម៌ ( PJ ) ហើយបានចែកម្ហូបអាហារកញ្ចប់ដល់អ្នកទោស និង ឆ្មាំពន្ធនាគារជាស្ត្រីផងដែរ។

## សកម្មភាពក្នុងសហគមន៍

ជនបង្គោលបានបើកវគ្គបណ្តុះបណ្តាលផ្លូវការ និងក្រៅផ្លូវការ ដើម្បីលើកកំពស់ការយល់ដឹងស្តីពីអំពើហិង្សាលើស្ត្រី។ វគ្គក្រៅផ្លូវការធ្វើឡើង ដោយបានការចូលរួមពីសមាជិកសហគមន៍ជាង ៩៥៨នាក់។ វគ្គនេះធ្វើឡើងនៅតាមទីផ្សារ តាមរយៈការពិភាក្សាលើបញ្ហាអំពើហិង្សាលើស្ត្រី ក្នុងអំឡុងពេលសំរាកទទួលទានអាហារ និងការសន្ទនាជាមួយអ្នកជិតខាង មិត្តភ័ក្ត និង ក្រុមគ្រួសារ។



វគ្គលើកកំពស់ការយល់ដឹងក្នុងសហគមន៍

ចំណែកវគ្គហ្វឹកហ្វឺនផ្លូវការវិញ ធ្វើឡើងរយៈពេល៤ខែ (ពីខែធ្នូ ឆ្នាំ២០០៦ ដល់ខែសីហា ឆ្នាំ២០០៧) ដោយបានការចូលរួមពីសមាជិកសហគមន៍ប្រហែល ១.៥០៧នាក់។ វគ្គហ្វឹកហ្វឺនទាំងនេះត្រូវបានរៀបចំដោយជនបង្គោល ដោយមានជំនួយបច្ចេកទេសពីការិយាល័យសិទ្ធិស្ត្រី។ វគ្គនេះលើកឡើងអំពីព័ត៌មានទាក់ទងនឹងសិទ្ធិស្ត្រី អំពើហិង្សាលើស្ត្រី និង ច្បាប់ផ្សេងៗដែលពាក់ព័ន្ធ។

**ចំនួនអ្នកចូលរួមទទួលការហ្វឹកហ្វឺនពីជនបង្គោល**




# វេទិកាសហគមន៍

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ អង្គការលីកាដូបានបង្កើតវេទិកាសហគមន៍ ដើម្បីបញ្ចប់គមរោងសាកល្បងឆ្នាំទី១របស់ខ្លួន នៅក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាល។ មានអ្នកចូលរួមក្នុងវេទិកានោះចំនួន ៥០នាក់ មកពីស្រុកអង្គស្នួល ដោយមានជាជនបង្គោល ៣១នាក់ មន្ត្រីមូលដ្ឋាន ១៤នាក់ សមាជិកសហគមន៍ ៥នាក់ និង បុគ្គលិកអង្គការលីកាដូ ១៨នាក់។

វេទិកានេះមានគោលបំណងបង្ហាញនូវមតិយោបល់នានាពីអ្នកចូលរួមទាំងអស់ ស្ដីពីវគ្គបណ្ដុះបណ្ដាល និងគំរោងសាកល្បង បានបង្ហាញនូវលទ្ធផល និងធ្វើសេចក្ដីសន្និដ្ឋានលើការវាយតំលៃ។ លទ្ធផលនៃការវាយតំលៃត្រូវបានបង្ហាញដល់អ្នកចូលរួមក្នុងគំរោងសាកល្បង តាមរយៈការសំដែងល្ខោនរឿងខ្លី (Drama) ដែលរួមបញ្ចូលទាំងលទ្ធផល និងយោបល់ពីសំណាក់សមាជិកសហគមន៍។ អត្ថបទរឿងល្ខោនខ្លីមាននៅក្នុងឧបសម្ព័ន្ធទី១។




វេទិកាសហគមន៍ក្នុងស្រុកអង្គស្នួល

# ៤. ការវាយតំលៃ

ការវាយតំលៃលើគំរោងសាកល្បងត្រូវបានធ្វើឡើងពីខែមករា ដល់ ខែមេសា ឆ្នាំ២០០៧។ ជនបង្គោល និង មន្ត្រីមូលដ្ឋាន ដែលបានចូលរួមវគ្គបណ្តុះបណ្តាល និងសមាជិកសហគមន៍នៅក្នុងភូមិទាំង៨[២] ត្រូវបានរាប់បញ្ចូល នៅក្នុងដំណាក់កាលប្រមូលទិន្នន័យនេះ។

មានមនុស្សចំនួន ១៦៣នាក់ ត្រូវបានធ្វើសម្ភាសន៍ ដែលមានជនបង្គោល ៣៩នាក់ មន្ត្រីមូលដ្ឋាន ១៦នាក់ និង សមាជិកសហគមន៍ ១០៩នាក់។ ក្នុងចំណោមសមាជិកសហគមន៍ដែលបានសម្ភាសន៍ មានបុរសចំនួនតែ ៦នាក់ប៉ុណ្ណោះ ហើយក្រុមសម្ភាសន៍មានបំណងធ្វើការវាយតំលៃលើស្ត្រី ដោយហេតុថាបុរសភាគច្រើនចេញទៅប្រកបរបរក្រៅភូមិ ពេលដែលក្រុមការងារចុះទៅធ្វើការងារនេះ។

បុគ្គលិកអង្គការលីកាដូ ២នាក់បានធ្វើសម្ភាសន៍ជាមួយជនបង្គោលទាំងអស់ចំនួន៣៩នាក់ ចំនួនបីលើកក្នុងខែមករា កុម្ភៈ និង មិនា ឆ្នាំ២០០៧។

សមាជិកក្រុមសម្ភាសន៍ទាំងអស់មានចំនួន ១៨នាក់ ដែលបែងចែកជា៨ក្រុម ដោយមានអ្នកដឹកនាំក្រុម ៣នាក់ ប្រធានក្រុមធំ ១នាក់ ដើម្បីទទួលខុសត្រូវក្នុងការសម្ភាសន៍សមាជិកសហគមន៍ និងមន្ត្រីមូលដ្ឋានក្នុងថ្ងៃ២៧ ខែមេសា ឆ្នាំ២០០៧។ ក្រុមការងារបានធ្វើសម្ភាសន៍ជាមួយអ្នករស់នៅក្នុងសហគមន៍តាមផ្ទះដោយជ្រើសរើសចោះៗ នឹងបែងចែកចំនួនសមាជិករបស់ខ្លួនក្នុងការធ្វើបទសម្ភាសន៍តាមភូមិនីមួយៗដោយស្មើៗគ្នា។

សំណួរសំរាប់សម្ភាសន៍/ទំរង់វាយតំលៃ ដែលក្រុមការងារយកមកប្រើ មាននៅក្នុងឧបសម្ព័ន្ធទី៣ ដល់ ទី៥ ក្នុងរបាយការណ៍នេះ។ មានទំរង់វាយតំលៃត្រូវ៧ចំនួន៣ផ្សេងទៀត ដែលទំរង់មួយប្រភេទសំរាប់ជនបង្គោល មួយប្រភេទទៀតសំរាប់មន្ត្រីមូលដ្ឋានដែលបានចូលរួមវគ្គបណ្តុះបណ្តាល និងមួយប្រភេទផ្សេងទៀតសំរាប់សមាជិកទូទៅនៅក្នុងសហគមន៍។

ការប្រើប្រាស់ទំរង់វាយតំលៃ គឺក្នុងគោលបំណងលសាកល្បងប៉ាន់ប្រមាណលើផលប៉ះពាល់របស់គំរោងសាកល្បងនេះលើជនបង្គោល។ ព័តិមានសំខាន់ៗដែលត្រូវស្វែងរករួមមាន:

[២] សូមអានផ្នែកនៃរបាយការណ៍នេះស្តីពីជនបង្គោល

- ផលប៉ះពាល់នៃវគ្គបណ្តុះបណ្តាលលើជនបង្គោល និងមន្ត្រីមូលដ្ឋាន (ការផ្លាស់ប្តូរគំនិត និងអត្តចរិត លើករណីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ)។
- ការផ្លាស់ប្តូរនូវសកម្មភាពរបស់ជនបង្គោល និងមន្ត្រីមូលដ្ឋាន ចំពោះជនរងគ្រោះដោយសារអំពើហិង្សានៅក្នុងសហគមន៍។
- ថាតើមាន ឬមិនមានការបង្កើនទំនាក់ទំនងការងាររវាងជនបង្គោល និងមន្ត្រីមូលដ្ឋាន ជាអាទិភាពចំពោះករណីប្រព្រឹត្តអំពើហិង្សាលើស្ត្រីជាអាទិភាព។
- ថាតើកម្មវិធីអប់រំនិងសកម្មភាពលើកកំពស់ការយល់ដឹង ដែលជនបង្គោលបានបង្កើតឡើង បានជះឥទ្ធិពលលើអំពើហិង្សាលើស្ត្រីនៅក្នុងសហគមន៍។
- ថាតើគំរោងសាកល្បងទាំងមូលបានចូលរួមផ្លាស់ប្តូរចរិត ចំណេះដឹង និង សកម្មភាពបុគ្គលម្នាក់ៗ នៅក្នុងសហគមន៍ ចំពោះជនរងគ្រោះដោយសារអំពើហិង្សា និងប្រធានបទអំពីអំពើហិង្សាលើស្ត្រី។
- តើគំរោងសាកល្បងទាំងមូលបានចូលរួមកាត់បន្ថយការប្រព្រឹត្តហិង្សាលើស្ត្រីនៅក្នុងសហគមន៍។

## ដែនកំណត់នៃការវាយតំលៃ

ក្រុមការងារមិនបានធ្វើសម្ភាសន៍ជាមួយមន្ត្រីមូលដ្ឋាន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលទាំងអស់ទេ ដោយមន្ត្រីខ្លះបានបញ្ជូនតំណាងរបស់ខ្លួនមកឆ្លើយនឹងសំនួរ។ ហេតុដូច្នេះ មានតែមន្ត្រីមូលដ្ឋានចំនួន ១៦នាក់ ប៉ុណ្ណោះ ក្នុងចំណោម ២៣នាក់ ដែលបានចូលរួមវគ្គបណ្តុះបណ្តាល បានផ្តល់សម្ភាសន៍ ហើយពួកគេជាអ្នកតំណាងឱ្យមន្ត្រីមូលដ្ឋានដែលបានចូលរួមវគ្គបណ្តុះបណ្តាលទាំងអស់។

បុគ្គលិកអង្គការលីកាដូបានសម្ភាសន៍ជនបង្គោលទាំងអស់ ប្រមទាំងមន្ត្រីមូលដ្ឋាន និងសមាជិកសហគមន៍ខ្លះផងដែរ។ បទសម្ភាសន៍ទាំងនេះប្រហែលជាពុំទាន់ធ្វើឡើងឱ្យចំគោលដៅនៅឡើយទេ ហើយជាពិសេសជនបង្គោលក៏ប្រហែលជាពុំមានអារម្មណ៍កក់ក្តៅក្នុងការផ្តល់ចំលើយឱ្យទូលំទូលាយដែរ។

សូមអានលទ្ធផល និង សេចក្តីសន្និដ្ឋានលើកាវាយតំលៃមាននៅក្នុងឧបសម្ព័ន្ធទី២។

□□□

# ៥. លទ្ធផលសំរេច

## លទ្ធផលសំរេច

គំរោងនេះទទួលបានជោគជ័យក្នុងការអប់រំជនបង្គោលស្តីពីអំពើហិង្សាលើស្ត្រី និងកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅក្នុងសហគមន៍ដែលបានជ្រើសរើស ។ លទ្ធផលសំរេចបានគួរឱ្យកត់សំគាល់មានដូចជាៈ

- ការពង្រឹងទំនាក់ទំនងរវាងសមាជិកគំរោង និងអាជ្ញាធរដែនដី សមាជិកគំរោង និងជនបង្គោល ព្រមទាំងជនបង្គោល និងអាជ្ញាធរដែនដី ។
- ការកំណត់ជនបង្គោលដែលមានឆន្ទៈខ្ពស់ក្នុងការជួយស្ត្រីនៅក្នុងភូមិ ។
- សកម្មភាពទាំងអស់ត្រូវបានបញ្ចប់ ទោះបីជាការអនុវត្តសកម្មភាពទាំងនោះ មានការយឺតយ៉ាវជាងការគ្រោងទុកក៏ដោយ ។
- ជនបង្គោលយើងបានយល់ថាអំពើហិង្សាលើស្ត្រីជាអំពើខុសច្បាប់ និងមិនមែនជាបញ្ហាផ្ទៃក្នុងទេ តែជាបញ្ហារួមរបស់សហគមន៍ ។
- អ្នកភូមិចាប់ផ្តើមចេះផ្តល់ព័ត៌មានដល់ជនបង្គោល មន្ត្រីមូលដ្ឋាន និងអង្គការលីកាដូនៅពេលដែលមានករណីអំពើហិង្សាលើស្ត្រីកើតឡើង ។
- ជនបង្គោល និងមន្ត្រីមូលដ្ឋានយល់យ៉ាងច្បាស់អំពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងសហគមន៍ ។
- ជនបង្គោល មន្ត្រីមូលដ្ឋាន និងសមាជិកសហគមន៍នៅតែបន្តផ្តល់ព័ត៌មានចំពោះករណីអំពើហិង្សាលើស្ត្រីមកអង្គការលីកាដូ ទោះបីជាគំរោងបានបញ្ចប់ក៏ដោយ ។

ចំពោះលទ្ធផលសំរេចបានផ្សេងទៀត មាននៅក្នុងលទ្ធផលលើការវាយតំលៃ សូមអានក្នុងឧបសម្ព័ន្ធទី២ ។

□□□

# ឧបសម្ព័ន្ធទី១:  សាច់រឿងល្ខោនសំរាប់សំដែងក្នុងឱកាស ទិវាសហគមន៍

**សកម្មភាពចុងក្រោយសំរាប់គំរោងសាកល្បងនៅក្នុងស្រុកអង្គស្នួល ខេត្តកណ្តាល**

ស្រ្តីមួយក្រុមបានអង្គុយជុំគ្នានៅខាងក្រៅ ដោយកំពុងបោកគក់ នឹងកំពុងនិយាយដើមគ្នាបណ្តើរ ។

- **ក:**-តើថ្ងៃនេះឯងបានឃើញប្រពន្ធរបស់ ស៊ីម ដែរឬទេ-នាងមានស្នាមជាំពេញនៅលើផ្ទៃមុខ។ ខ្ញុំគិតថា នាងត្រូវប្តីវាយធ្វើបាបសារជាថ្មីទៀតហើយ ។
- **ខ:**-ឱ! ប្អូនស្រីអើយ ! ស៊ី ស៊ី ស៊ី ប្អូនកុំនិយាយអាក្រក់អំពីអ្នកជិតខាងរបស់យើងបែបនេះ អីម្យ៉ាងវិញទៀត នេះគឺរឿងផ្ទៃក្នុងដែលគ្រួសារគេត្រូវដោះស្រាយដោយខ្លួនគេទេ ។
- **ក:**-អំពើហិង្សានៅក្នុងគ្រួសារមិនមែនជាបញ្ហាផ្ទៃក្នុងទេ តែជាបញ្ហារបស់សង្គម ហើយយើងទាំងអស់គ្នាត្រូវដឹងថា យើងត្រូវជួយជនរងគ្រោះ។ មនុស្សម្នាក់ៗត្រូវដឹងថាអ្នកណា ដែលវាយធ្វើបាបប្រពន្ធកូននឹងត្រូវផ្តន្ទាទោសតាមច្បាប់ ។
- **ខ:**-តើប្អូនដឹងរឿងនេះដោយរបៀបណា ? បើប្អូនមិនមែនជាមេធាវីផង ។ តើប្អូនគិតថា ប្អូនដឹងគ្រាន់បើជាងមនុស្សផ្សេងៗទៀតនៅក្នុងភូមិរបស់យើងឬ ?
- **ក:**-នោះ ន់ **គ** មកដល់ល្មម នាងជាសមាជិកនៃក្រុមថ្មីរបស់ជនបង្គោល។ ជាក្រុមដែលជួយស្ត្រីដែលជាជនរងគ្រោះដោយអំពើហិង្សា ។ តោះ យើងទៅសួរមើល តើនាងគិតយ៉ាងម៉េចដែរ ?
- **ក:**-អេ! **គ** មកចូលរួមជាមួយយើង ពួកយើងកំពុងតែជជែកអំពីអំពើហិង្សានៅក្នុងគ្រួសារ និងនៅក្នុងភូមិយើង ហើយពួកយើងកំពុងតែមិនយល់ស្របគ្នាទេ ។ សូមមកអង្គុយជជែកជាមួយយើង !
  - មានស្រ្តីជាច្រើននាក់ចូលរួម ហើយសុំឱ្យនាងចូលរួមជាមួយពួកគេដែរ ។
  - ប្រហែលជាយើងសុំឱ្យមានជនបង្គោលដែលមកពីស្ថានីយផ្សព្វផ្សាយវិទ្យុ ៨មិនាសំដែង **គ** ។

- **គ:**-មែនហើយខ្ញុំមានពេលទំនេរខ្លះដែរ ។ ខ្ញុំទើបតែប្រជុំចប់ជាមួយជនបង្គោលជាច្រើនទៀតមកពីស្រុកអង្គស្នួល ។ យើងកំពុងពិភាក្សាអំពីសកម្មភាពមួយចំនួន ដែលយើងនឹងត្រូវធ្វើនៅខែក្រោយ ដើម្បីបង្រៀនប្រជាជនអំពីអំពើហិង្សានឹងបញ្ហាមកលើស្ត្រី ។

- **ឃ:**- ហ្អេ គ ពួកយើងទើបតែកំពុងជជែកអំពីស៊ីម និងប្រពន្ធគាត់ ។ យើងទាំងអស់គ្នាដឹងថាពួកគេកំពុងមានបញ្ហាខ្លះៗ ក៏ប៉ុន្តែខ្ញុំគិតថា ពួកយើងគួតែកុំជ្រៀតជ្រែកកិច្ចការរបស់គេ ហើយទុកឱ្យគ្រួសារគេដោះស្រាយបញ្ហានេះដោយខ្លួនគេទៅ ។

- **ក:**-ខ្ញុំគិតថាពួកយើងគួតែទៅនិយាយជាមួយប្រពន្ធរបស់ស៊ីម ឱ្យដឹងថា តើពួកយើងអាចជួយនាងបានដូចម៉េចខ្លះ ?

- **គ:**-មិនងាយស្រួលទេ ខ្ញុំចង់និយាយថា មុននឹងខ្ញុំក្លាយជាជនបង្គាលហើយទទួលបានការបណ្តុះបណ្តាលអំពីសិទ្ធិស្ត្រី ខ្ញុំធ្លាប់មានការភ័យខ្លាចមិនចង់ធ្វើអន្តរាគមន៍នៅក្នុងរឿងអំពើហិង្សានៅក្នុងគ្រួសារទេ នៅក្នុងករណីនោះ ខ្ញុំក៏ត្រូវគេវ៉ាយដែរ ដូច្នេះខ្ញុំមិនធ្វើទេ ។

- **ខ:**- មែនហើយខ្ញុំក៏ជឿអញ្ចឹងដែរ ខ្ញុំមិនចង់បង្កើតបញ្ហាឱ្យខ្លួនឯង និងគ្រួសាររបស់ខ្ញុំ ដោយសារតែទៅជ្រៀតជ្រែកកិច្ចការរបស់អ្នកដ៏ទៃនោះទេ ។

- **គ:**- ក៏ប៉ុន្តែ **ខ** បើសិនជាយើងទាំងអស់គ្នាធ្វើបែបនេះ មានស្ត្រីនិងកុមារជាច្រើននឹងទទួលការឈឺចាប់នៅក្នុងសហគមន៍របស់យើង ។ ឥឡូវបើខ្ញុំដឹងឮអំពីអំពើហិង្សាណាមួយ ខ្ញុំនឹងរាយការណ៍ទៅឃុំ ឬប្រធានភូមិ ដើម្បីធ្វើអន្តរាគមន៍ ខ្ញុំក្លាហានជាងពីមុន ពីព្រោះនៅពេលករណីនេះកើតឡើង ខ្ញុំអាចទៅរារាំងអំពើហិង្សា អប់រំ នឹង ធ្វើអន្តរាគមន៍ដល់អាជ្ញាធរមូលដ្ឋាន ឬក៏ទូរសព្ទ័ទៅអង្គការក្រៅរដ្ឋាភិបាលដែលជាប់ពាក់ពន្ធ័ ។ ខ្ញុំមានជំរើស ជនបង្គោលផ្សេងទៀតក៏មានជំរើស ហើយពួកយើងជាសហគមន៍ផងដែរ ។ ពួកយើងមានជំរើសដើម្បីព្យាយាមបញ្ឈប់អំពើហិង្សាឱ្យទាល់តែបាន ។




ឆាកល្ខោនដែលបានសំដែងក្នុងវេទិការសហគមន៍នៅស្រុកអង្គស្នួល

- **ក៖**-ខ្ញុំគិតថា អ្នកនិយាយអញ្ចឹងត្រូវហើយនៅក្នុងការធ្វើអន្តរាគមន៍នៅក្នុងករណីទាំងនេះ ក៏ប៉ុន្តែអ្នកជាជនបង្គោល អ្នកមានការអបរំច្រើនអំពីសិទ្ធិស្ត្រី ហើយអ្នកទទួលបានការគាំទ្រច្រើន។ ខ្ញុំចង់ជួយប្រពន្ធរបស់ស៊ឹម ប៉ុន្តែខ្ញុំគ្រាន់តែជាស្ត្រីមេផ្ទះធម្មតា ដែលមិនចេះអាន ឬ សរសេរអក្សរផង តើឱ្យខ្ញុំទៅបញ្ឈប់ស៊ឹមមិនឱ្យវាយធ្វើបាបប្រពន្ធកូនរបស់គាត់យ៉ាងម៉េច?

- **គ៖**-ប៉ុន្តែ... ខ្ញុំក៏ជាស្ត្រីមេផ្ទះធម្មតាដែរ ហើយពីមុនខ្ញុំមិនដែលគិតថា ខ្ញុំមានអំណាចក្នុងការបញ្ឈប់អំពើហិង្សាមិនឱ្យកើតឡើងនៅក្នុងគ្រួសាររបស់ខ្ញុំទេ។ ខ្ញុំចង់ប្រាប់រឿងមួយដល់អ្នក ប្តីរបស់ខ្ញុំធ្លាប់វាយធ្វើបាបខ្ញុំរាល់ថ្ងៃ រយៈពេល៥ឆ្នាំចុងក្រោយនេះ។ ឱ! ជីវិតមានការលំបាកខ្លាំងណាស់ គាត់តែងតែខឹងនឹងខ្ញុំ ហើយច្រើនតែប្រាប់ខ្ញុំថា ខ្ញុំមិនមែនជាប្រពន្ធល្អម្នាក់ទេ ។ គាត់វាយធ្វើបាបខ្ញុំដោយសារតែមិនដាំបាយឱ្យបានលឿនសំរាប់គាត់ ឬមិនបានសន្សំលុយខ្លះ ទិញសំលៀកបំពាក់ខ្លះៗឱ្យកូន ម្យ៉ាងវិញទៀតត្រូវឱ្យលុយគាត់។ ខ្ញុំតែងតែក្រៀមក្រំចិត្តខ្លាំងណាស់នឹងអស់សង្ឃឹមទៀតដែរ។

- **ឃ៖**-វាក៏ដូចជារឿងរបស់ខ្ញុំដែរ គឺរៀងរាល់ថ្ងៃ...

- **ខ៖**-ក្រោយមកមានថ្ងៃមួយ គេបានសុំខ្ញុំចូលរួមក្នុងបណ្តាញក្រុមថ្មីនៃជនបង្គោល ដែលអ្នករាល់គ្នាដឹងនេះ។ ខ្ញុំបានជួបស្ត្រីជាច្រើនក្នុងក្រុមនេះដូចខ្ញុំដែរ ពួកគេមិនមានការអបរំច្រើនទេ ប៉ុន្តែពួកគេដឹងពីរបៀបបញ្ឈប់អំពើហិង្សានៅក្នុងផ្ទះនិងនៅក្នុងភូមិ។ ខ្ញុំបានរៀនច្រើនណាស់ ! ខ្ញុំដឹងថា ធ្វើជាស្ត្រី ឬជាមនុស្ស ខ្ញុំមានសិទ្ធិមិនឱ្យគេវាយធ្វើបាប នឹងមិនរស់នៅដោយសេចក្តីភ័យខ្លាចទេ។ ខ្ញុំបានដឹងថា យើងមានច្បាប់នៅក្នុងប្រទេសកម្ពុជាដែលការពារសិទ្ធិទាំងនេះ នៅពេលណាដែលមនុស្សវាយធ្វើបាបយើង នឹងរំលោភបំពានសិទ្ធទាំងនេះ ពួកគេប្រឆាំងនឹងច្បាប់ ហើយអាចត្រូវគេផ្តន្ទាទោស។ ខ្ញុំបានដឹងថា ប្រសិនបើក្មេងស្រីម្នាក់ ត្រូវបានគេចាប់រំលោភ វាមិនមែនជាកំហុសរបស់នាងទេ ពីព្រោះនាងមិនបានយល់ព្រមចំពោះទង្វើនេះឡើយ។ ខ្ញុំបានរៀនអំពីលទ្ធភាពក្នុងការធ្វើដំណើរដោយសុវត្ថិភាពទៅកាន់កន្លែងផ្សេងៗ ដើម្បីឱ្យខ្ញុំមិនស្ថិតនៅក្នុងគ្រោះថ្នាក់ជួញដូរ ឬបង្ខំដែលប្រឆាំងនឹងឆន្ទៈរបស់ខ្ញុំ។ ខ្ញុំនិងជនបង្គោលផ្សេងៗទៀតបានសន្យាថា យើងនឹងចែករំលែកនូវរាល់អ្វីដែលយើងបានរៀនជាមួយសមាគមន៍របស់យើង។

- **ក៖**-ដូច្នេះគ តើអ្នកចង់និយាយថាម៉េច ដែលមនុស្សគ្រប់រូបអាចរៀនពីរបៀបបញ្ឈប់អំពើហិង្សា ?

- **គ:**-មែនហើយ ខ្ញុំមិនទាន់និយាយចប់រឿងរបស់ខ្ញុំនៅឡើយទេ។ ប្តីរបស់ខ្ញុំបានចាប់ផ្តើមវាយធ្វើបាបខ្ញុំម្តងទៀតក្នុងរយៈពេលពីរ ឬ បីសប្តាហ៍បន្ទាប់ពីខ្ញុំបានក្លាយជាជនបង្គោល។ ខ្ញុំភ័យខ្លាចខ្លាំងមែនទែន ប៉ុន្តែសព្វថ្ងៃខ្ញុំមានសេចក្តីក្លាហានច្រើនបន្តិច។ ខ្ញុំបានសំរេចចិត្តប្រាប់គាត់នូវអ្វីដែលខ្ញុំបានរៀនអំពីសិទ្ធិរបស់ខ្ញុំ និងអំពីរបៀបដែលប្រឆាំងនិងច្បាប់ចំពោះគាត់ក្នុងការដែលគាត់បានវាយធ្វើបាបខ្ញុំ។ លើកដំបូងគាត់គ្រាន់តែសើចដាក់ខ្ញុំ ក៏ប៉ុន្តែ រៀងរាល់ថ្ងៃ ខ្ញុំនិយាយទៅកាន់គាត់អំពីអ្វីដែលខ្ញុំបានកំពុងរៀន ហើយមានថ្ងៃណាមួយគាត់ពិតជាបានបញ្ឈប់ និងស្តាប់ខ្ញុំ។ ខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ ! ប៉ុន្តែ ខ្ញុំនៅតែបន្តការនិយាយហើយ និយាយទៀត រហូតដល់គាត់ពិតជាឈប់វាយធ្វើបាបខ្ញុំ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ។ ទីបំផុតខ្ញុំ បានធ្វើឱ្យប្តីរបស់ខ្ញុំយល់ថា អំពើហិង្សាលើជនណាម្នាក់គឺជារឿងអាក្រក់មួយ។

- **ខ:**- គួរឱ្យភ្ញាក់ផ្អើលមែនទែន **គ** ! ដែលអ្នកចាត់ចែងធ្វើរឿងនេះបានរយៈពេលមួយថ្ងៃ ?

- **គ:**-ទេ មិនមែនទេ ! វាប្រើពេលវេលាយូរណាស់ ប្រហែលជាពីរ ឬ បីខែ ក៏ប៉ុន្តែរាល់ថ្ងៃ ខ្ញុំបាននិយាយកាន់តែច្រើនឡើងៗ ធ្វើឱ្យប្តីខ្ញុំវាយខ្ញុំកាន់តែតិចទៅៗ រហូតមានថ្ងៃមួយ គាត់ឈប់។ ហើយនោះគឺជាអ្វីដែលអាចផ្លាស់ប្តូរសហគមន៍របស់យើងបាន ! ចូរនឹកស្រមៃមើល ប្រសិនបើប្រពន្ធរបស់ស៊ុម អាចនិយាយទៅកាន់ប្តីរបស់នាងអំពីការឈឺចាប់និង សិទ្ធិរបស់នាង ឬ បើសិនជាខ្ញុំ ឬ យើងម្នាក់ៗបាននិយាយ ឬ ក៏យើងទាំងអស់គ្នាបានចូលរួមជួយបង្រៀនគាត់ នោះយើងអាចព្យាយាមបញ្ឈប់គាត់មិនឱ្យនាងឈឺចាប់ទៀតទេ ។

- **ឃ:**-អ្វីដែលអ្នកកំពុងនិយាយ ខ្ញុំយល់ហើយ **គ**។ ខ្ញុំអាចយល់បានថា ចាប់តាំងពីក្រុមជនបង្គោលបានចាប់ផ្តើមកើតឡើង អ្នករាល់គ្នាកំពុងតែជួយជនរងគ្រោះដោយអំពើហិង្សា។ ពួកយើងទាំងអស់ជឿជាក់លើអ្នកហើយ អញ្ជើញយើងនិងទៅរកអ្នកនៅពេលយើងត្រូវការជំនួយ។ អ្នកដឹងទេពួកយើងអាម៉ាស់ណាស់ ពេលដែលអំពើហិង្សាកើតមាននៅក្នុងសហគមន៍របស់ពួកយើង ក៏ប៉ុន្តែសំរាប់យើងគ្រប់គ្នា ពួកយើងមិនឃើញមានដំណោះស្រាយណាមួយចំពោះបញ្ហានេះទេ ។

- **ខ:-ឃ** ត្រូវហើយ អ្នកជាជនបង្គោលអាចធ្វើអន្តរាគមន៍ នៅក្នុងករណីមានអំពើហិង្សា ប៉ុន្តែក្រោយមកធ្វើយ៉ាងម៉េចទៀត ? អ្នកចាកចេញពីយើង ដែលជាអ្នកភូមិហើយបន្ទាប់មក យើងត្រូវដោះស្រាយបញ្ហាទាំងមូល ? តើអ្នកអាចជួយបានអ្វីខ្លះ ?

- **គៈ**-មែនហើយ ជាដំបូង គឺយើងអាចផ្ដល់ព័ត៌មានជាច្រើនឱ្យអ្នកស្ដីពីសិទ្ធិរបស់អ្នកជាស្ត្រី ហើយនិងច្បាប់ដែលការពារសិទ្ធិទាំងនេះ។ នោះជាមូលហេតុដែលជនបង្គោលទាំងអស់នៅ ស្រុកអង្គស្នួលកំពុងត្រូវបានគេផ្ដល់សិក្ខាសាលាអប់រំជាច្រើនរយៈពេល៦ខែកន្លងទៅនេះ ហើយរឿងមួយទៀតគឺថាយើងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន យើងនឹងអាចធ្វើការជាមួយគ្នា ដើម្បីជួយជនរងគ្រោះដោយផ្ដល់ជំរកស្នាក់នៅដល់ពួកគេ អប់រំជនល្មើស នឹងបញ្ចប់អំពើហិង្សា ។
- **កៈ**-មានតែអាជ្ញាធរមូលដ្ឋានទេឬ ? តើពួកគេធ្លាប់បានជួយអ្វីខ្លះដល់ពួកយើង នៅពេលយើងត្រូវការឱ្យពួកគេជួយនោះ ?
- **គៈ**-អ្នកភ្ញាក់ផ្អើលណាស់ **ក!** អាជ្ញាធរមូលដ្ឋានក៏ទទួលការអប់រំនិងការបណ្ដុះបណ្ដាលដូចជនបង្គោលដែរ។ ពួកគេបានរៀនច្រើនណាស់ហើយក៏ផ្លាស់ប្ដូរអកប្បកិរិយារបស់ពួកគេផងដែរ។ **ក** ជាប្រធានភូមិម្នាក់ដែលខ្ញុំធ្វើការជាមួយ។ គាត់ធ្លាប់ស្ទាក់ស្ទើរក្នុងការធ្វើអន្តរាគមន៍ក្នុងករណីអំពើហិង្សានៅក្នុងគ្រួសារ។ ក៏ប៉ុន្តែរយៈពេល ២ និង ៣ ខែចុងក្រោយនេះ រាល់ពេលដែលខ្ញុំបានទៅរកគាត់ គាត់បានជួយខ្ញុំ និង ជនរងគ្រោះក្នុងការព្យាយាមដោះស្រាយជំលោះ។ គាត់បានប្រាប់ថាគាត់មានទំនុកចិត្តខ្លាំងណាស់ក្នុងការព្យាយាមដោះស្រាយជំលោះ ហើយកាត់ដឹងថា អំពើហិង្សាធ្វើឱ្យសង្គមទាំងមូលមានការព្រួយបារម្ភណ៍ ដូច្នេះយើងត្រូវការដោះស្រាយបញ្ហានេះទាំងអស់គ្នា ។
- កៈ-ប៉ុន្តែនោះមានមន្ត្រីមូលដ្ឋានតែម្នាក់ទេ។ ហើយចុះអាជ្ញាធរផ្សេងទៀត ?
- **គៈ**-មែនហើយ មានជនបង្គោលក្នុងចំណោមពួកគេ ដែលរស់នៅក្នុងភូមិដ៏ទៃទៀត បានប្រាប់ខ្ញុំថានៅក្នុងភូមិរបស់គាត់ អាជ្ញាធរមូលដ្ឋាន មិនរើសអើងនឹងជនរងគ្រោះទេ ហើយខំប្រឹងជួយពួកគេទៀតផង។ ជួនកាលអាជ្ញាធរមូលដ្ឋានទាំងអស់នោះក៏ផ្ដល់ជំរកដល់ជនរងគ្រោះឱ្យស្នាក់នៅមួយយប់ ឬ ពីរយប់ទៀតផង។ ជនបង្គោលម្នាក់បានប្រាប់ខ្ញុំថា គាត់កំពុងធ្វើការលើករណីនេះជាមួយអាជ្ញាធរមូលដ្ឋានម្នាក់។ ពីមុននាងធ្លាប់ខ្លាចគាត់ណាស់ ហើយនាងមានអារម្មណ៍ថា គាត់និយាយខ្លាំងៗ ហើយមិនបានយល់ពីអំពើហិង្សាឡើយ។ ក្រោយមកគាត់រមទម្យណាស់ ហើយក៏បាននិយាយដោយរីករាយទៅកាន់ជនរងគ្រោះ ហើយគាត់បានព្យាយាមផ្ដល់ទំនុកចិត្តដល់ជនរងគ្រោះទៀតផង ដើម្បីឱ្យជនរងគ្រោះអាចប្រាប់គាត់អំពីរឿងរបស់នាង។ ជនបង្គោលនោះគួរឱ្យភ្ញាក់ផ្អើលខ្លាំងណាស់ ប៉ុន្តែគួរឱ្យរីករាយមែនទែន ! យើងទាំងអស់គ្នាមានអារម្មណ៍ថា អាជ្ញាធរមូលដ្ឋាន នៅក្នុងសហគមន៍របស់យើង កំពុងធ្វើការជាមួយយើងនិងខិតខំលុបបំបាត់អំពើហិង្សា ។

- **ឃៈ**-អេ ! ស្តាប់ទៅគួរឱ្យចាប់អារម្មណ៍ ហើយល្អទៀតផង ។ អ្នកដឹងទេ ប្តីរបស់បងស្រីខ្ញុំធ្វើការនៅទីចាត់ការឃុំ ហើយគាត់បានប្រាប់នាងថា មនុស្សនៅកន្លែងធ្វើការគាត់កំពុងនិយាយថា អំពើហិង្សានៅក្នុងសហគមន៍របស់យើងបានធ្លាក់ចុះហើយ ។ តើអ្នកគិតថា នេះជាការពិតដែរឬទេ?

- **កៈ**-ប្រហែលជាអញ្ចឹង ! បើសិនជាអាជ្ញាធរមូលដ្ឋាន និងជនបង្គោលទាំងអស់កំពុងតែធ្វើការទៅលើសំណុំរឿងអំពីអំពើហិង្សា បានអប់រំ និងរារាំងមិនឱ្យមានអំពើហិង្សាកើតមាននោះវាត្រឹមត្រូវហើយ ។ ដូចពួកម៉ាកខ្ញុំឈ្មោះសុខា បានប្រាប់ខ្ញុំថា នាងកំពុងនិយាយទៅកាន់សិក្ខាកាមដែលបានចូលរួមសិក្ខាសាលាអំពីជនបង្គោល ហើយពួកគេបានដឹងថា វាខុសក្នុងការវាយធ្វើបាបនរណាម្នាក់ ។ ដូច្នេះ ពួកគេបានចែកចាយព័ត៌មាននេះជាមួយសុខា ហើយនាងបានសំរេចចិត្តឈប់វាយធ្វើបាបកូនៗរបស់នាង ។

- **គៈ**-ចាស! មនុស្សជាច្រើនបានមករកខ្ញុំហើយបានប្រាប់ខ្ញុំថា នៅក្នុងភូមិរបស់យើងមានចំនួនអំពើហិង្សាតិចជាងពីមុន ។ វាធ្វើឱ្យខ្ញុំសប្បាយចិត្តខ្លាំងណាស់ ប៉ុន្តែ ខ្ញុំដឹងថាយើងគ្រប់គ្នាមានការងារច្រើនណាស់ ត្រូវធ្វើជាមួយសហគមន៍និមួយៗ ។

- **ខៈ**-តើយើងអាចធ្វើអ្វីខ្លះដើម្បីជួយ ?

- **គៈ**-តើអ្នកគិតយ៉ាងដូចម្តេច ថាអ្នកអាចធ្វើបាននោះ ?

- **ឃៈ**-មែនហើយ ប្រហែលជាយើងអាចចាប់ផ្តើមធ្វើ ដោយរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ឱ្យស៊ើបអង្កេតលើករណីនេះ ហើយបញ្ឈប់គាត់មិនឱ្យវាយធ្វើបាបប្រពន្ធរបស់គាត់ទៀត ។ ក្រោយមកយើងអាចនិយាយទៅកាន់ប្រពន្ធរបស់គាត់ផងដែរ ហើយត្រូវប្រាកដថា នាងយល់ព្រម នឹងដឹងថាពួកយើងនឹងអាចធ្វើអ្វីខ្លះដើម្បីជួយនាង ។ ខ្ញុំនឹងទៅនិយាយ អំពីរឿងនេះប្រសិនអ្នករាល់គ្នាមកជាមួយខ្ញុំ ?

- **ខៈ**-អុ!...អូ!...(ស្ទាក់ស្ទើរមិនប្រាកដ)

- **កៈ**-តោះ **ខ!** តើយើងបានកំពុងជជែកអំពីអ្វីរយៈពេលមួយសន្ទុះធំនេះ ? មានមនុស្សម្នាក់ ត្រូវការជួយប្រពន្ធរបស់ស៊ីម ហើយវាគួរតែជាយើងជាអ្នកជិតខាងរបស់នាង ! ប្រសិនបើជាយើងទាំងអស់គ្នាទៅប្រហែលជាយើងអាចជួយអាជ្ញាធរជាមួយប្រពន្ធស៊ីម និងកូនៗគាត់ ។ ... អាចទៅជាមួយយើង ពីព្រោះនាងស្គាល់អាជ្ញាធរមូលដ្ឋាន ។

- **ខ**-តោះ អ្នកនិយាយត្រូវហើយប្រសិនជាខ្ញុំត្រូវគេវាយធ្វើបាប ខ្ញុំក៏ចង់ធ្វើឱ្យនរណាម្នាក់មកជួយខ្ញុំ ជាមួយនិងស្ថានភាពបែបនេះដែរ ដើម្បីបញ្ឈប់អំពើហិង្សានេះ ។
- **គ**:-ត្រូវហើយ ពីព្រោះយើងគ្រប់គ្នាដឹងថា អំពើហិង្សា គឺជាបញ្ហារបស់សហគមន៍ទាំងមូល មិនមែនបញ្ហាបុគ្គលទេ ។ យើងដឹងថា ប្រសិនបើជាយើងរួមដៃគ្នាទាំងជនបង្គោល អាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ យើងប្រាកដជាអាចធ្វើការរួមគ្នា ដើម្បីបញ្ឈប់អំពើហិង្សា។ ប្រហែលជាថ្ងៃមួយកូនរបស់យើងធំឡើងនឹងមានគ្រួសាររបស់គេ ហើយពេលនោះអំពើហិង្សានឹងមានចំនួនតិចជាងឥឡូវ ។
- **ក**:-ខ្ញុំក៏សង្ឃឹមថា វានិងអាចកើតមាននៅថ្ងៃណាមួយមែនទេ **គ**។
- **ខ និង ឃ**:- ខ្ញុំក៏យល់អញ្ចឹងដែរ

**ពួកគេទាំងអស់ នាំគ្នាដើរឆ្ពោះទៅកាន់ការិយាល័យរបស់អាជ្ញាធរមូលដ្ឋាន ។**

**បញ្ចប់ឈុតឆាកសំដែង ។**

□□□

# ឧបសម្ព័ន្ធទី២: លទ្ធផលនៃការវាយតំលៃ

## លទ្ធផលនៃការវាយតំលៃលើជនបង្គោល (ពីខែមករា – កុម្ភៈ – មិនាឆ្នាំ២០០៧)

***ចំណុចសំខាន់ៗ:***

ក្នុងពេលសម្ភាសន៍រៀងរាល់ខែ ជនបង្គោលភាគច្រើនបានរៀបរាប់ថា ពួកគេបានផ្តល់ជំនួយដល់ជនរងគ្រោះដោយអំពើហិង្សាបានយ៉ាងមានប្រសិទ្ធិភាព។ នៅខែមករា និង កុម្ភៈមានចំលើយ២៦ ដែលថាការផ្តល់ជំនួយទាំងនោះមានប្រសិទ្ធិភាពយ៉ាងខ្លាំង នៅមានចំលើយ ៣៩ផ្សេងទៀត ដែលថាការផ្តល់ជំនួយមានប្រសិទ្ធិភាពជាមធ្យម ហើយក៏មានជនបង្គោល១នាក់ដែលមានប្រសាសន៍ថាការផ្តល់ជំនួយរបស់ខ្លួនពុំមានប្រសិទ្ធិភាពទេ។ នៅខែមិនា ជនបង្គោលចំនួន ១៧នាក់ បានមានប្រសាសន៍ថាការផ្តល់ជំនួយរបស់ខ្លួនមានប្រសិទ្ធិភាពយ៉ាងខ្លាំង រីឯជនបង្គោល ១៥នាក់ទៀត ថាការផ្តល់ជំនួយរបស់ខ្លួនមានប្រសិទ្ធិភាពជាមធ្យម។

- នៅពេលដែលយើងបានសាកសួរអំពីការផ្លាស់ប្តូរអត្តចរឹតរបស់ជនបង្គោលចំពោះអំពើហិង្សាលើស្ត្រី បន្ទាប់ពីបានទទួលនូវវគ្គបណ្តុះបណ្តាល យើងបានរកឃើញនូវចំណុចរួមមួយចំនួនដូចខាងក្រោម:

  - ខ្ញុំចេះពីវិធីធ្វើអន្តរាគមន៍ ឬផ្តល់ព័ត៌មានដល់មេភូមិ ឬមេឃុំ នៅពេលដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើង។
  - ឥឡូវនេះខ្ញុំយល់ច្បាស់ថា អំពើហិង្សាក្នុងគ្រួសារមិនមែនជាបញ្ហាផ្ទៃក្នុងទេ តែវាជាបញ្ហារបស់សង្គម ហើយអ្នកដែលប្រព្រឹត្តអំពើហិង្សានេះនឹងត្រូវបញ្ជូនទៅពន្ធនាគារទៅតាមទង្វើរបស់ខ្លួន។
  - ខ្ញុំមានសេចក្តីក្លាហានជាងមុន ព្រោះថាពេលមានរឿងកើតឡើង ខ្ញុំអាចទប់ស្កាត់ អប់រំ និងធ្វើអន្តរាគមន៍ដល់អាជ្ញាធរដែនដី ឬក៏ទូរស័ព្ទទៅកាន់អង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ។
  - កាលពីមុន ខ្ញុំខ្លាចថានៅពេលដែលខ្ញុំចុះធ្វើអន្តរាគមន៍លើករណីអំពើហិង្សាក្នុងគ្រួសារ ខ្ញុំនឹងត្រូវគេវាយដែរ ដូច្នេះហើយបានជាខ្ញុំមិនហ៊ានធ្វើអន្តរាគមន៍ ប៉ុន្តែឥឡូវនេះខ្ញុំចេះរាយការណ៍ទៅកាន់មេភូមិ ឬ ក៏មេឃុំឱ្យចុះធ្វើអន្តរាគមន៍។
  - ខ្ញុំមានការយល់ដឹងច្រើនអំពីអំពើហិង្សាលើស្ត្រី។ ខ្ញុំរឹងប៉ឹង ហើយមានសេចក្តីក្លាហាន ហ៊ាននិយាយពេលដែលមានអំពើហិង្សាកើតឡើង ហើយខ្ញុំអាចអប់រំអ្នកនៅក្នុងសហគមន៍អំពី

ច្បាប់។ ប្រសិនបើមានអំពើហិង្សាកើតឡើង ខ្ញុំប្រាកដជាសហការជាមួយមេភូមិ និងប៉ូលីសឱ្យចុះអន្តរាគមន៍ និងទាក់ទងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ។

- ខ្ញុំបានបញ្ឈប់អំពើហិង្សាលើកូនរបស់ខ្ញុំ ហើយខ្ញុំបានប្រាប់ក្រុមគ្រួសារ អ្នកជិតខាង និងអ្នកនៅក្នុងសហគមន៍ថា យើងមិនត្រូវប្រើអំពើហិង្សាលើកូនរបស់យើងទេ។

- នៅពេលដែលយើងបានសាកសួរអំពីឧទាហរណ៍ពីការផ្លាស់ប្តូរទាំងនោះ បន្ទាប់ពីបានទទួលការបំពាក់បំប៉នពីគំរោងមកយើងបានរកឃើញនូវចំណុចរួមមួយចំនួនដូចខាងក្រោម:

  - មុនពេលមិនទាន់មានការបង្កើតគំរោងសាកល្បង ប្តីខ្ញុំធ្លាប់វាយធ្វើបាបប្រពន្ធនិងកូន ប៉ុន្តែឥឡូវនេះ គាត់គ្រាន់តែជេរស្តីឱ្យប៉ុណ្ណោះ។
  - កាលពីមុននៅក្នុងភូមិរបស់ខ្ញុំមានអំពើហិង្សាក្នុងគ្រួសារកើតឡើងលើគ្រួសារចំនួន១០ ប៉ុន្តែឥឡូវនេះបានកាត់បន្ថយបាន៥០% ហើយដោយសារតែអ្នកភូមិយល់ដឹងអំពីអំពើហិង្សាក្នុងគ្រួសារ បន្ទាប់ពីពួកគេបានសិក្សាពីអង្គការលីកាដូ។
  - អ្នកភូមិយល់ដឹងពីច្បាប់ ប្រសិនបើគាត់វាយគេ គាត់នឹងត្រូវផ្តន្ទាទោស និងបញ្ជូនទៅកាន់ពន្ធនាគារ។
  - ករណីអំពើហិង្សាក្នុងគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរមិនដែលកើតឡើងទៀតទេ នៅពេលដែលយើងបានទទួលចំណេះដឹងពីអង្គការលីកាដូ។
  - ចាប់តាំងពីគំរោងបានចាប់ផ្តើមមក ខ្ញុំមិនដែលឃើញអំពើហិង្សាក្នុងគ្រួសារកើតឡើងក្នុងភូមិខ្ញុំឡើយ។ យើងផ្សព្វផ្សាយព័ត៌មានដល់សហគមន៍រាល់ខែ ហើយអ្នកភូមិយល់ដឹងពីអំពើហិង្សា និងហ៊ានប្តឹង ហើយពួកគាត់ក៏បានស្វែងរកការប្រឹក្សាយោបល់ពីសំណាក់ជនបង្គោល និងមន្ត្រីមូលដ្ឋានផងដែរ។
  - បុរសដែលធ្លាប់ផឹកស្រាកន្លងមក ឥឡូវនេះពុំសូវទទួលទានច្រើនដូចមុនទេ។
  - មុនពេលមិនទាន់មានការបង្កើតគំរោង ក្នុងភូមិខ្ញុំមានការវាយតប់គ្នាជាច្រើន ប៉ុន្តែឥឡូវនេះបានកាត់បន្ថយហើយ ដោយសារតែពួកគេជាច្រើនយល់ដឹងពីអំពើហិង្សាតាមរយៈអង្គការលីកាដូ និងជនបង្គោល យល់ដឹងពីច្បាប់នានាដូចជាច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារជាដើម ព្រមទាំងខ្លាចទទួលទោសផងដែរ។
  - នៅពេលដែលមានអំពើហិង្សាកើតឡើង អ្នកភូមិរត់មកពឹងពាក់យើង (ជនបង្គោល) ព្រោះពួកគាត់មានទំនុកចិត្តលើយើង។
  - មន្ត្រីមូលដ្ឋានបានសហការយ៉ាងល្អក្នុងការអប់រំសហគមន៍ និងទប់ស្កាត់អំពើហិង្សា។

**ស្ថិតិសំខាន់ៗ (ពីខែ មករា ដល់ មិនា ២០០៧)**

**តារាង: ជនបង្គោលផ្តល់ជំនួយដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងសហគមន៍**

| ការផ្តល់ជំនួយ | ចំនួនដង |
|---|---|
| ជូនជនរងគ្រោះទៅប្តឹង | ៨ |
| ផ្តល់ការប្រឹក្សាដល់ជនរងគ្រោះ | ៧៩ |
| សរសេរពាក្យបណ្តឹង | ១ |
| ដាក់ពាក្យបណ្តឹង | ៦ |
| ជំនួយផ្សេងៗទៀត | ២១ |

**តារាង: កន្លងមកតើគំរោងការងារនេះបានកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍អ្នកបានកំរិតណា?**

| កំរិតកាត់បន្ថយអំពើហិង្សា | ចំលើយរបស់ជនបង្គោល |
|---|---|
| ច្រើន | ៥១ |
| មធ្យម | ៥៤ |
| តិច | ១ |

**តារាង: ការអប់រំសំរាប់សហគមន៍ដែលគ្មានប្រសិទ្ធិភាពសោះ**

| ការអប់រំគ្មានប្រសិទ្ធិភាពបំផុត | ចំលើយរបស់ជនបង្គោល |
|---|---|
| ការអប់រំផ្លូវការ (សិក្ខាសាលា ។ល។) | ១៦ |
| ការអប់រំក្រៅផ្លូវការ | ២០ |
| បណ្តាញព័ត៌មាន (ការផ្សាយតាមវិទ្យុ) | ៤៥ |
| ផ្សេងៗ | ១០ |

ស្ថិតិទាំងនេះមិនត្រូវគ្នានឹងចំលើយលើសំណួរដែលលើកឡើងថា "តើការអប់រំរបៀបណាដែលមានប្រសិទ្ធិភាពបំផុតនៅក្នុងសហគមន៍របស់អ្នក" ដោយជនបង្គោលបានឆ្លើយថា វគ្គបណ្តុះបណ្តាលផ្លូវការ និងក្រៅផ្លូវការសុទ្ធតែមានប្រសិទ្ធិភាពបំផុតនៅក្នុងសហគមន៍របស់គាត់។

ភាពមិនស៊ីចង្វាក់នេះអាចបណ្តាលមកពីការផ្តល់ចំលើយលើការវាយតំលៃ ដោយជនបង្គោលត្រូវឆ្លើយនឹងសំនួរជ្រើសរើសដែលគាត់ប្រហែលជាមិនចង់ជ្រើសរើស។ ចំពោះការវាយតំលៃលើកក្រោយ ចំលើយទាំងនេះគួរតែលុបចោល។

**សេចក្តីសន្និដ្ឋាន**

- សរុបមកជនបង្គោលភាគច្រើនហាក់បីដូចជាទទួលបានចំណេះដឹងកាន់តែច្រើនអំពីសិទ្ធិស្ត្រី និងច្បាប់ដែលទាក់ទងនឹងអំពើហិង្សាលើស្ត្រីបន្ទាប់ពីបានចូលរួមក្នុងគំរោងមក។
- សរុបមកជនបង្គោលភាគច្រើនបានផ្លាស់ប្តូរអត្តចរិតរបស់ខ្លួនចំពោះអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាលើស្ត្រី ដោយគាត់យល់ថាអំពើហិង្សាក្នុងគ្រួសារមិនមែនជាបញ្ហាផ្ទៃក្នុងរបស់គ្រួសារឡើយ និងក៏ចេះអន្តរាគមន៍នៅពេលដែលករណីអំពើហិង្សាកើតឡើងផងដែរ។
- សរុបមកជនបង្គោលភាគច្រើនកំពុងផ្តល់ការអប់រំទាំងផ្លូវការនិងក្រៅផ្លូវការដល់សហគមន៍របស់ខ្លួនអំពីបញ្ហា អំពើហិង្សាលើស្ត្រី។
- ហាក់បីដូចជាមានភស្តុតាងដែលបង្ហាញពីការសហការគ្នារវាងមន្ត្រីមូលដ្ឋាន និងជនបង្គោលតែក្នុងពីរ-បីភូមិប៉ុណ្ណោះ។

## លទ្ធផលនៃការវាយតំលៃលើមន្ត្រីមូលដ្ឋាន (ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧)

*ចំនុចសំខាន់ៗ:*

- មន្ត្រីមូលដ្ឋានទាំង ១៦នាក់ បានឆ្លើយក្នុងបទសម្ភាសន៍ថាស្ត្រីជាជនរងគ្រោះដោយអំពើហិង្សា (អំពើហិង្សាគ្រួសារ ករណីរំលោភសេពសន្ថវៈ និងករណីជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវភេទ) បានមកសុំជំនួយពីគាត់។
- នៅពេលដែលយើងបានសាកសួរអំពីការផ្លាស់ប្តូរអត្តចរិតរបស់មន្ត្រីមូលដ្ឋានចំពោះអំពើហិង្សាលើស្ត្រី បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាល យើងបានរកឃើញនូវចំណុចរួមមួយចំនួនដូចខាងក្រោម:
  - គាត់យល់ថាអំពើហិង្សាជាបញ្ហាសង្គមទាំងមូល ដូច្នេះយើងត្រូវតែជួយដោះស្រាយបញ្ហានេះទាំងអស់គ្នា។

- មានការផ្លាស់ប្តូរអត្តចរិត បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលពីអង្គការលីកាដូ។
- មានទំនុកចិត្តច្រើនក្នុងការដោះស្រាយជំលោះដែលពីមុនមកគាត់នៅមានការស្ទាក់ស្ទើរ។

• នៅពេលដែលយើងបានសាកសួរអំពីការប្រែប្រួលចំពោះចំណេះដឹងរបស់មន្ត្រីមូលដ្ឋានចំពោះអំពើហិង្សាលើស្ត្រី បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាល យើងបានរកឃើញនូវចំណុចរួមមួយចំនួនដូចខាងក្រោមៈ
  - ខ្ញុំយល់ច្បាស់ជាងមុនថាអំពើហិង្សាមានផលប៉ះពាល់ដល់សង្គម។
  - វាមានសារៈសំខាន់ណាស់ដែលត្រូវធ្វើការអប់រំសហគមន៍ និងរាយការរាល់ករណីអំពើហិង្សាទៅកាន់ឃុំ។
  - យើងត្រូវតែកាត់បន្ថយការវាយតប់គ្នា។

• នៅពេលដែលយើងបានសាកសួរអំពីភាពខុសគ្នាចំពោះអត្តចរិត និងសកម្មភាពរបស់មន្ត្រីមូលដ្ឋានចំពោះជនរងគ្រោះ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាល យើងបានរកឃើញនូវចំណុចរួមមួយចំនួនដូចខាងក្រោមៈ
  - ខ្ញុំយកចិត្តទុកដាក់ជួយជនរងគ្រោះ និងអប់រំជនល្មើស ដោយឱ្យជនល្មើសធ្វើកិច្ចសន្យាឈប់ប្រើអំពើហិង្សាតទៅទៀត។
  - ខ្ញុំមិនរើសអើងចំពោះជនរងគ្រោះឡើយ តែខ្ញុំព្យាយាមជួយគាត់ ដោយពេលខ្លះ ខ្ញុំផ្តល់កន្លែងស្នាក់នៅពីរបីយប់ជូនគាត់។
  - ខ្ញុំបានចាប់ផ្តើមដោះស្រាយបញ្ហាសំខាន់ភ្លាមៗ ព្រមទាំងបានតាមដានចំពោះការប្តឹងរបស់ជនរងគ្រោះដែរ។
  - ខ្ញុំប្រើពាក្យសំដីទន់ភ្លន់ទៅកាន់ជនរងគ្រោះដើម្បីកុំឱ្យគាត់ភ័យខ្លាច ហើយខ្ញុំក៏ព្យាយាមធ្វើឱ្យគាត់មានទំនុកចិត្តក្នុងការបង្ហាញនូវអារម្មណ៍របស់គាត់ដែរ។

• នៅពេលដែលយើងបានសាកសួរអំពីឧទាហរណ៍ពីការផ្លាស់ប្តូរទាំងនោះ បន្ទាប់ពីបានទទួលការបំពាក់បំប៉នពីគំរោងមក មន្ត្រីមូលដ្ឋាន ១១នាក់ ក្នុងចំណោម ១៦នាក់ បានប្រាប់យើងថា អំពើហិង្សាលើស្ត្រីមានចំនួនធ្លាក់ចុះហើយ។

**ស្ថិតិសំខាន់ៗ**

**តារាង: អាជ្ញាធរដែនដីផ្តល់ជំនួយដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងសហគមន៍**

| ការផ្តល់ជំនួយ | ចំនួន |
|---|---|
| ជួយប្តឹង | ១ លើក |
| អន្តរាគមន៍អំពើហិង្សា | ៦ លើក |
| សរសេរពាក្យបណ្តឹង | ១ លើក |
| ផ្តល់ជំរើសដោះស្រាយជំលោះ (ផ្សះផ្សាគ្នា) | ១១ លើក |
| ផ្សះផ្សាភាគីទាំងពីរ | ២ លើក |
| នាំជនរងគ្រោះទៅកន្លែងមានសុវត្ថិភាព និងដាក់ពិន័យជនល្មើស | ៤ លើក |
| ពន្យល់ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារទៅកាន់ភាគីទាំងពីរ | ៤ លើក |

**តារាង: តើអ្នកកំពុងបង្កើតបណ្តាញសហគមន៍ជាមួយអាជ្ញាធរដែនដីផ្សេងទៀតទេ?**

| បាទ/ចាស | ទេ |
|---|---|
| ១៤ | ២ |

**តារាង: កន្លងមកតើគំរោងការងារនេះបានកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍អ្នកបានកំរិតណា?**

| កំរិតកាត់បន្ថយអំពើហិង្សា | ចំលើយរបស់មន្ត្រីមូលដ្ឋាន |
|---|---|
| ច្រើន | ១១ |
| មធ្យម | ៤ |
| តិច | 0 |

**សេចក្តីសន្និដ្ឋាន**

- សរុបមកអាជ្ញាធរដែនដីភាគច្រើនហាក់បីដូចជាទទួលបានចំណេះដឹងកាន់តែច្រើនអំពីសិទ្ធិស្ត្រី និងច្បាប់ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី បន្ទាប់ពីបានចូលរួមក្នុងគំរោងមក។

- សរុបមកអាជ្ញាធរដែនដីភាគច្រើនបានផ្លាស់ប្តូរអត្តចរិតរបស់ខ្លួនចំពោះអំពើហិង្សាក្នុងគ្រួសារ និង អំពើហិង្សាលើស្ត្រីបន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលរួចមក។
- សរុបមកអាជ្ញាធរដែនដីភាគច្រើនកំពុងផ្លាស់ប្តូរសកម្មភាព និងអត្តចរិតរបស់ខ្លួនចំពោះជនរងគ្រោះ ដោយសារអំពើហិង្សាក្នុងគ្រួសារ រំលោភសេពសន្ថវៈ និងជួញដូរស្ត្រីក្នុងគោលបំណងអាជីវកម្មផ្លូវ ភេទ ដោយគ្មានការរើសអើង និងទទួលយកករណីអំពើហិង្សាមកធ្វើការស៊ើបអង្កេត ធ្វើការណែនាំ អំពីសិទ្ធិរបស់ភាគីនីមួយៗ ផ្តល់ប្រឹក្សាយោបល់ក្នុងជំលោះ និងបង្កើនការយល់ដឹងបន្ថែមទៀត អំពីជនរងគ្រោះ។
- សរុបមកអាជ្ញាធរដែនដីភាគច្រើនកំពុងធ្វើការរួមគ្នាលើអំពើហិង្សាលើស្ត្រី ប៉ុន្តែមិនបានបញ្ជាក់អំពី ការសហការជាមួយជនបង្គោលទេ។ ទោះបីជាយើងមិនបានសួរសំនួរនេះឱ្យចំក៏ដោយ តែយើង អាចប៉ាន់ស្មានបានថា អាជ្ញាធរដែនដីមួយចំនួនប្រហែលជាកំពុងធ្វើការជាមួយជនបង្គោលទាក់ទង នឹងអំពើហិង្សាលើស្ត្រី ប៉ុន្តែយើងមិនរំពឹងថាគេនឹងផ្តល់ព័ត៌មាននេះទេ។

## លទ្ធផលនៃការវាយតំលៃលើសមាជិកសហគមន៍ (ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧)

***ចំនុចសំខាន់ៗ:***

- សមាជិកសហគមន៍ ១០២នាក់ ដែលបានសម្ភាសន៍បានដឹងថាមានបណ្តាញជនបង្គោលស្ត្រីធ្វើការលើ ករណីអំពើហិង្សានៅក្នុងភូមិរបស់ខ្លួន។ ដោយសារតែសមាជិកសហគមន៍ ១០២នាក់ ដែលយើង សម្ភាសន៍ជាស្ត្រី បានជាមានការពិបាកក្នុងការវាយតំលៃលើឥទ្ធិពលយេនឌ័ររបស់ពួកគាត់ក្នុងស្ថិតិ នេះ។ យើងនឹងទទួលបាននូវលទ្ធផលផ្សេងពីនេះ ប្រសិនបើមានការសម្ភាសន៍ជាមួយសមាជិក សហគមន៍ជាបុរស។
- សមាជិកសហគមន៍ ៩២នាក់ បានចូលរួមកម្មវិធីអប់រំនិងលើកកំពស់ការយល់ដឹងរបស់ជនបង្គោល ក្នុងនោះ យើងទទួលបាននូវមតិមួយចំនួនដូចខាងក្រោម:
  - ខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាល ហើយខ្ញុំបានប្រាប់អ្នកជិតខាងខ្ញុំពីអំពើហិង្សាលើស្ត្រី។
  - ខ្ញុំព្យាយាមធ្វើការសំរុះសំរួលជាមួយអ្នកប្រព្រឹត្តអំពើហិង្សាក្នុងភូមិ ហើយខ្ញុំក៏បានផ្តល់ការ ប្រឹក្សាយោបល់ និងផ្តល់កន្លែងស្នាក់នៅដល់ជនរងគ្រោះដែរ។
- នៅពេលដែលយើងបានសាកសួរអំពីឧទាហរណ៍ពីការផ្លាស់ប្តូរនៅក្នុងសហគមន៍ បន្ទាប់ពីបានទទួល ការបំពាក់បំប៉នពីគំរោងមក ប្រជាពលរដ្ឋ៦២នាក់ បានឆ្លើយថាអ្នកជិតខាងរបស់គាត់តែងតែមាន ការឈ្លោះទាស់ទែងគ្នាក្នុងគ្រួសារ ប៉ុន្តែបន្ទាប់ពីទទួលការអប់រំពីអង្គការលីកាដូមក ជំលោះទាំង

នោះក៏បានកាត់បន្ថយ ។ នេះជាបញ្ហា ដែលគួរពិចារណា ដោយសារតែយើងពុំអាចផ្តល់ភាពត្រឹមត្រូវលើចំលើយនោះបានឡើយ ។ ទន្ទឹមនឹងនោះ យើងក៏បានទទួលនូវចំលើយផ្សេងទៀតដែលមានដូចខាងក្រោម:

- ខ្ញុំធ្លាប់ប្រើអំពើហិង្សាលើប្រពន្ធខ្ញុំ ប៉ុន្តែឥឡូវនេះខ្ញុំបានកាត់បន្ថយហើយ ។
- ឥឡូវនេះយើងដឹងពីច្បាប់ ហើយយើងឈប់ជេរស្តីនិងមើលងាយប្រពន្ធយើងទៀតហើយ ។
- ខ្ញុំខ្លាចច្បាប់និងគុក ដូច្នេះហើយខ្ញុំឈប់ជេរស្តី វាយដំ និងមើលងាយប្រពន្ធខ្ញុំទៀតហើយ ។
- កាលពីមុន គ្មានការអន្តរាគមន៍ចំពោះអំពើហិង្សាដែលកើតឡើងទេ តែឥឡូវនេះស្ថានភាពគឺខុសគ្នា ដោយអ្នកនៅក្នុងសហគមន៍យល់ច្បាស់នឹងចេះជួយគ្នា ។
- យើងមានការខ្មាស់អៀនចំពោះអ្នកប្រព្រឹត្តអំពើហិង្សា ។
- យើងបន្តអប់រំអ្នកដែលប្រព្រឹត្តអំពើហិង្សាក្នុងសហគមន៍ ។
- ប្រសិនបើមានអំពើហិង្សាណាមួយកើតឡើង យើងអាចស្វែងរកជំនួយពីមេភូមិនិងអ្នកដ៏ទៃទៀត ។
- ប្តីខ្ញុំតែងតែប្រើអំពើហិង្សាមកលើខ្ញុំ ហើយខ្ញុំក៏ស្វែងរកជំនួយពីអង្គការលីកាដូនិងស្នាក់នៅទីនោះបានមួយរយៈ ។ ដោយប្តីខ្ញុំទទួលការអប់រំ គាត់បានផ្លាស់ប្តូរច្រើនណាស់ ដោយគាត់ឈប់ប្រើអំពើហិង្សាមកលើខ្ញុំទៀតហើយ ។
- ឥឡូវនេះមេភូមិ និងមេឃុំចុះអន្តរាគមន៍នៅពេលដែលមានបញ្ហាហិង្សាកើតឡើង ។
- ឥឡូវនេះខុសពីមុន ដោយសារអ្នកភូមិមានការយល់ដឹងច្រើនអំពីស្ថានការ និងស្ថានភាពជនរងគ្រោះ ហើយមន្ត្រីមូលដ្ឋានក៏មានវិធីសាស្ត្រជាច្រើនក្នុងការទប់ស្កាត់អំពើហិង្សាដែរ ។
- វាជារឿងល្អមួយនៅក្នុងសហគមន៍របស់យើង ឥឡូវនេះ មិនសូវកើតមានអំពើហិង្សាក្នុងសហគមន៍ទេ ។

• នៅពេលដែលយើងបានសាកសួរដល់សមាជិកសហគមន៍អំពីការពេញចិត្តរបស់គាត់ ក្នុងការស្វែងរកជំនួយពីសំណាក់មន្ត្រីមូលដ្ឋាន នៅពេលដែលមានករណីអំពើហិង្សាលើស្ត្រីកើតឡើងសមាជិកសហគមន៍ ៩៥នាក់ បានឆ្លើយថាពួកគេមានការពេញចិត្តក្នុងការស្វែងរកជំនួយពីមន្ត្រីមូលដ្ឋាន ។ ស្ថិតិដ៏ខ្ពស់នេះអាចបណ្តាលមកពីសមាជិកសហគមន៍មិនហ៊ានផ្តល់ចំលើយស្មោះត្រង់ ដែលអាចប៉ះពាល់ដល់មន្ត្រីមូលដ្ឋានរបស់ពួកគេ ។ ទន្ទឹមនឹងនោះ យើងក៏ទទួលបានយោបល់មួយចំនួនទៀតដែលមានដូចខាងក្រោម:

- យើងពឹងផ្អែកលើប្រធានក្នុងមូលដ្ឋានដែលគាត់អាចជួយយើងបាន ។

- នេះជាការជួយជនរងគ្រោះឱ្យចៀសផុតពីអំពើហិង្សា ។
- ចំពោះបញ្ហាខ្លះខ្ញុំអាចដោះស្រាយបានដោយខ្លួនឯង ប៉ុន្តែបើបញ្ហានោះធ្ងន់ធ្ងរ ខ្ញុំត្រូវតែរកជំនួយពីអាជ្ញាធរដែនដី ។

- យោបល់ទូទៅ: ប្រជាពលរដ្ឋ ៤៨នាក់ បានរៀបរាប់ថា ចង់ឱ្យអង្គការលីកាដូបង្កើតវគ្គបណ្តុះបណ្តាលបន្ថែមទៀត ដើម្បីជាជំនួយសំរាប់សហគមន៍ ។ រួមមានយោបល់មួយចំនួនទៀតដូចជា:
  - ចង់ឱ្យបុរសនិងស្ត្រីចូលរួមវគ្គបណ្តុះបណ្តាលទាំងអស់គ្នា ។
  - ចង់ឱ្យប៉ូលីសឈប់ទទួលយកសំណូក និងមិនត្រូវជួយតែអ្នកមានទេ ។
  - ចង់រស់នៅក្នុងសន្តិភាព ។
  - ចង់កាត់បន្ថយអំពើហិង្សា តែមិនចង់ឱ្យមានអ្នកណាខឹងគាត់ពេលដែលគាត់ធ្វើអន្តរាគមន៍ ។

**ស្ថិតិសំខាន់ៗ**

**តារាង: តើអ្នកដឹងពីបណ្តាញការងារលើអំពើហិង្សាលើស្ត្រីតាមវិធីណា?**

| សកម្មភាព | ចំលើយរបស់សហគមន៍ |
|---|---|
| ចូលរួមក្នុងសកម្មភាពបណ្តាញ | ៤៧ |
| ទទួលការអប់រំពីមន្ត្រីមូលដ្ឋាន | ៤៤ |
| ឮតាមរយៈអ្នកជិតខាង | ២២ |
| មានជំនួយពីសមាជិកសហគមន៍ផ្សេងទៀត | ២២ |
| ផ្សេងៗ | ៥ |

**តារាង: តើអ្នកគិតថាអាជ្ញាធរដែនដីកំពុងធ្វើការដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅក្នុងភូមិរបស់អ្នក? ហេតុអ្វី?**

| បាទ/ចាស | ទេ |
|---|---|
| ៧៩ | ៣ |

*យោបល់:*

- ប្រជាពលរដ្ឋ ៥៦នាក់ឆ្លើយថា ឥឡូវនេះអាជ្ញាធរចុះអន្តរាគមន៍ និងអប់រំប្រជាពលរដ្ឋអំពីអំពើហិង្សា ផ្តល់ជាជំនួយឱ្យពួកគេចេះសំរុះសំរួលគ្នា ហើយប្រសិនបើ ជាភាគីជំលោះមិនស្តាប់ គាត់នឹងបញ្ជូនទៅកាន់ឃុំ ឬក៏អង្គការក្រៅរដ្ឋាភិបាល ។
- ហេតុផលពាក់ព័ន្ធនឹងស្ថិតិនេះ អាចបណ្តាលមកពីអាជ្ញាធរដែនដីកំពុងធ្វើការដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី ឬ អាចបណ្តាលមកពីសមាជិកសហគមន៍មិនហ៊ានផ្តល់ចំលើយស្មោះត្រង់ ដែលអាចប៉ះពាល់ដល់អាជ្ញាធរដែនដីរបស់ខ្លួន ។
- ហេតុផលមួយផ្សេងទៀតដែលជះឥទ្ធិពលលើស្ថិតិនេះអាចប្រហែលមកពីសមាជិកសហគមន៍ពុំមានទំនាក់ទំនងជាមួយអាជ្ញាធរដែនដី ដោយសារតែពួកគេគ្មានអ្វីទាក់ទងជាមួយអាជ្ញាធរដែនដីចំពោះករណីអំពើហិង្សាលើស្ត្រី ។

**តារាង: កន្លងមកតើគំរោងការងារនេះបានកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍អ្នកបានកំរិតណា?**

| កំរិតកាត់បន្ថយអំពើហិង្សា | ចំលើយរបស់សមាជិកសហគមន៍ |
|---|---|
| ច្រើន | ៥៥ |
| មធ្យម | ៣៧ |
| តិច | ១៦ |
| គ្មានការផ្លាស់ប្តូរ | ២ |

*យោបល់:*

*គំរោងនេះបានកាត់បន្ថយអំពើហិង្សាលើស្ត្រីក្នុងសហគមន៍បានច្រើនដោយសារ:*

- មានការអប់រំពីសំណាក់អង្គការនានា និងអាជ្ញាធរដែនដី ។
- ប្រជាពលរដ្ឋអាចស្វែងយល់ពីអំពើហិង្សាក្នុងគ្រួសារ តាមរយៈផ្ទាំងក្រដាស់ដែលបានចែកជូន ។
- ប្រសិទ្ធិភាពរបស់វគ្គបណ្តុះបណ្តាល ។
- យើងយល់កាន់តែច្បាស់អំពីអំពើហិង្សា ។

*គំរោងនេះបានកាត់បន្ថយអំពើហិង្សាលើស្ត្រីក្នុងសហគមន៍បានជាមធ្យមដោយសារ:*

- អ្នកភូមិយល់ដឹងពីច្បាប់ ។
- អ្នកភូមិបានទទួលចំណេះដឹងពីវគ្គបណ្តុះបណ្តាល និងសកម្មភាពផ្សព្វផ្សាយនានា ។

- អាជ្ញាធរដែនដីកំពុងតែជួយអប់រំអ្នកភូមិ។

**សេចក្តីសន្និដ្ឋាន**

- សរុបមកសមាជិកសហគមន៍ភាគច្រើនដែលបានសម្ភាសន៍ បានដឹងពីបណ្តាញជនបង្គោលនិងគំរោងសាកល្បងនៅក្នុងសហគមន៍របស់ខ្លួន។
- កម្មវិធីអប់រំនិងសកម្មភាពលើកកំពស់ការយល់ដឹងរបស់ជនបង្គោល (ទាំងផ្លូវការ និងក្រៅផ្លូវការ) ក៏បានជា ជំនួយក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រីនៅក្នុងសហគមន៍ទាំងនេះ។
- គំរោងសាកល្បងទាំងមូល ក៏បានជួយធ្វើឱ្យមានការផ្លាស់ប្តូរអត្តចរិត ការយល់ឃើញ និងសកម្មភាពសមាជិកសហគមន៍មួយចំនួន ចំពោះជនរងគ្រោះដោយសារអំពើហិង្សា និងចំពោះប្រធានបទអំពើហិង្សាលើស្ត្រីផងដែរ។ លើសពីនេះទៀត ប្រជាពលរដ្ឋជាច្រើនបានថ្លែងថាការអប់រំពីសំណាក់អាជ្ញាធរដែនដីបានជួយឱ្យពួកគាត់ផ្លាស់ប្តូរចំណុចទាំងនោះ។
- គំរោងសាកល្បងទាំងមូលនឹងបានជាជំនួយក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រីក្នុងសហគមន៍ ប្រសិនជាយើង ផ្អែកលើការវាយតំលៃលើសមាជិកដែលបានធ្វើសម្ភាសន៍ចំនួន ៥៥នាក់ក្នុងចំណោម ១០៩នាក់ដែលថា គំរោងនេះ បានកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍ជាច្រើន និងសមាជិក ៣៧នាក់ដែលថា គំរោងសាកល្បងនេះបានកាត់បន្ថយអំពើហិង្សាក្នុងសហគមន៍ជាមធ្យម។

## សេចក្តីសន្និដ្ឋានរួមលើការវាយតំលៃ

ផ្អែកលើលទ្ធផលនៃការវាយតំលៃលើជនបង្គោល អាជ្ញាធរដែនដីដែលបានចូលរួមវគ្គបណ្តុះបណ្តាល និងសមាជិកសហគមន៍ យើងអាចសន្និដ្ឋានបានថា គំរោងសាកល្បងហាក់ដូចជាមានឥទ្ធិពលលើអំពើហិង្សាលើស្ត្រីនៅក្នុងសហគមន៍ជាពិសេសៈ

- ជនបង្គោលបានទទួលបានចំណេះដឹងអំពីអំពើហិង្សាលើស្ត្រី ដោយពួកគេកំពុងផ្លាស់ប្តូរអត្តចរិតចំពោះអត្តចរិតអំពើហិង្សាលើស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សា។ ពួកគេកំពុងអន្តរាគមន៍ និងផ្តល់ជំនួយចំពោះករណីអំពើហិង្សាក្នុងគ្រួសារ សហការជាមួយអាជ្ញាធរដែនដីលើករណីអំពើហិង្សា និងកំពុងផ្តល់ការអប់រំដល់សហគមន៍របស់ខ្លួន (ទាំងផ្លូវការ និងក្រៅផ្លូវការ) ចំពោះករណីអំពើហិង្សាលើស្ត្រីផងដែរ។
- អាជ្ញាធរដែនដីបានទទួលបានចំណេះដឹងបន្ថែមអំពីអំពើហិង្សាលើស្ត្រី ដោយពួកគេកំពុងផ្លាស់ប្តូរអត្តចរិតចំពោះអំពើហិង្សាលើស្ត្រីនិងជនរងគ្រោះដោយសារអំពើហិង្សា។ ពួកគេកំពុងយកចិត្តទុកដាក់បន្ថែមដល់ជនរងគ្រោះ ធ្វើការអន្តរាគមន៍និងផ្តល់ជំនួយចំពោះករណីអំពើហិង្សា

ក្នុងគ្រួសារ (ដូចជាផ្ដល់ការប្រឹក្សាយោបល់ដល់ភាគីជំលោះឱ្យស្រុះស្រួលគ្នា ស៊ើបអង្កេតករណីផ្សេងៗ និងផ្ដល់ទីស្នាក់អាស្រ័យបណ្ដោះអាសន្នដល់ជនរងគ្រោះ) ធ្វើការសហការគ្នាលើករណីអំពើហិង្សារាយការណ៍ករណីនានាទៅមន្ត្រីថ្នាក់ឃុំ និងផ្ដល់ការអប់រំដល់សហគមន៍របស់ខ្លួនចំពោះករណីអំពើហិង្សាលើស្ត្រីផងដែរ ។

- សមាជិកសហគមន៍ក៏បានទទួលបានចំណេះដឹងបន្ថែមអំពីអំពើហិង្សាលើស្ត្រីនេះដែរ ដោយពួកគេកំពុងផ្លាស់ប្ដូរអត្តចរិតចំពោះអំពើហិង្សាលើស្ត្រីនិងជនរងគ្រោះដោយសារអំពើហិង្សា ។ ពួកគេកំពុងធ្វើការអន្តរាគមន៍ និងផ្ដល់ជំនួយចំពោះករណីអំពើហិង្សាក្នុងគ្រួសារ ធ្វើការរាយការណ៍ករណីនានាទៅជនបង្គោល និងអាជ្ញាធរដែនដី ព្រមទាំងកំពុងផ្ដល់ការអប់រំដល់អ្នកជិតខាង និងសហគមន៍របស់ខ្លួន ចំពោះករណីអំពើហិង្សាលើស្ត្រីផងដែរ ។

ផ្អែកតាមការវាយតំលៃនិងមតិយោបល់ពីសំណាក់ជនបង្គោល សមាជិកជនបង្គោលទាំងអស់ហាក់ដូចជាយល់ច្បាស់អំពីបញ្ហានានាដែលពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រី ជាពិសេសអំពើហិង្សាក្នុងសហគមន៍ហាក់ដូចជាបានកាត់បន្ថយ ហើយមានប្រជាពលរដ្ឋជាច្រើនកំពុងជួយជនរងគ្រោះ ជំនួសការដែលស្មានថាអំពើហិង្សាលើស្ត្រីជាបញ្ហាផ្ទៃក្នុង ។ ជនបង្គោលក្នុងស្រុកអង្គស្នួល ខេត្តកណ្ដាលហាក់បីដូចជាកំពុងធ្វើការជាសហគមន៍ ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី ។

□□□

# ឧបសម្ព័ន្ធទី៣: ទំរង់វាយតម្លៃជនបង្គោល

១. តើអ្នកធ្លាប់បានជួយអ្វីខ្លះ ដល់ជនរងគ្រោះដោយអំពើហិង្សានៅក្នុងសហគមន៍របស់អ្នក?

២. តើអ្នកគិតថា សកម្មភាពរបស់អ្នកមានប្រសិទ្ធិភាព ឬ គ្មានប្រសិទ្ធិភាព? ហេតុអ្វី? ឬ តើសកម្មភាពរបស់អ្នកមានប្រសិទ្ធិភាពកំរិតណាដែរ? ចូររៀបរាប់នូវប្រសិទ្ធិភាព ឬ កង្វះប្រសិទ្ធិភាពនៃសកម្មភាពរបស់អ្នក ។

៣. តាមគំនិត/យោបល់របស់អ្នក តើការអប់រំក្នុងទម្រង់បែបណាដល់សហគន៍របស់អ្នក ដែលមានប្រសិទ្ធិភាពជាទីបំផុតនោះ ?

៤. តាមគំនិត/យោបល់របស់អ្នក តើទំរង់អប់រំបែបណាមួយ ដែលពុំសូវមានប្រសិទ្ធិភាព ?

៥. តើឥរិយាបទរបស់អ្នកចំពោះបញ្ហាអំពើហិង្សាលើស្ត្រីបានផ្លាស់ប្តូរយ៉ាងណាខ្លះចាប់តាំងពីបានទទួលការហ្វឹកហ្វឺនកន្លងមក? ហេតុអ្វី ?

៦. ចាប់តាំងពីបានទទួលការហ្វឹកហ្វឺនកន្លងមក តើការយល់ដឹងអំពីអំពើហិង្សាលើស្ត្រី របស់អ្នកមានការផ្លាស់ប្តូរយ៉ាងណាខ្លះ? តើអ្វីខ្លះជាប្រភពនៃចំណេះដឹងថ្មីៗ ?

៧. កន្លងមក តើគម្រោងនេះបានជួយធ្វើការកាត់បន្ថយអំពើហិង្សានៅក្នុងសហគមន៍របស់អ្នកដល់កំរិតណាដែរ ? ចូរអ្នកពន្យល់អំពីការជួយកាត់បន្ថយនេះ ព្រមទាំងអោយឧទាហរណ៍ខ្លះៗអំពីអ្វីដែលបានផ្លាស់ប្តូរដោយសារគម្រោងនេះ នៅក្នុងសហគមន៍របស់អ្នក ?

□□□

# ឧបសម្ព័ន្ធទី៤: ទំរង់វាយតម្លៃអាជ្ញាធរមូលដ្ឋាន

ថ្ងៃ ខែ ឆ្នាំ:........................................................................................................................
ទីកន្លែង: ............................................................................................................................
ឈ្មោះមន្ត្រីមូលដ្ឋាន:.........................................................................................................
ឈ្មោះអ្នកសម្ភាសន៍:.........................................................................................................

**I- ផ្នែកទី ១**

១. មុខរបរជា

១/ កសិករ ☐

២/ កម្មករ ☐

៣/ សិស្សសាលា ☐

៤/ មេផ្ទះ ☐

៥/ មន្ត្រីរាជការ ☐

២. អាយុរបស់អ្នកសំភាសន៍

១/ ១៨ឆ្នាំ- ២៤ ឆ្នាំ ☐

២/ ២៥ឆ្នាំ- ៤0 ឆ្នាំ ☐

៣/ ៤១ឆ្នាំ ឡើង ☐

៣. ស្ថានភាពគ្រួសារ

១ / នៅលីវ ☐

២ / មានគ្រួសារហើយ ☐

៣/ មេម៉ាយ/ ពោះម៉ាយ ☐

៤. ភេទ

១ / ស្រី ☐

២/ ប្រុស ☐

៥. ការអប់រំ

១/ ចេះអាន និងសរសេរ ☐

២ / ចេះអានមិនចេះសរសេរ ☐

៣ / ចេះសរសេរ មិនចេះអាន ☐

៤ /មិនចេះអាន និងសរសេរ ☐

**II- ផ្នែកទី២**

៦- តើកន្លងមកមានជនរងគ្រោះ ដោយសារអំពើហិង្សាប្រឆាំងនឹងស្ត្រីមករកអ្នកឱ្យជួយដែរឬទេ ?

១/ មាន ☐

២/ ទេ ☐ (សូមបន្តទៅសំនួរទី ៩)

៧- តើអ្នកបានជួយអ្វីខ្លះ ដល់ជនរងគ្រោះដោយអំពើហិង្សាក្នុងសហគមន៍របស់អ្នក ?

១/ ជួយសរសេរពាក្យបណ្ដឹង ☐

២/ ការធ្វើអន្តរាគមន៍ ☐

៣/ សំរបសំរួល ☐

៤/ ផ្ដល់ប្រឹក្សា ☐

៥/ ផ្សេងៗ ☐មានអ្វីខ្លះ?..............................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

៨- តើការធ្វើអន្តរាគមន៍របស់អ្នកមានប្រសិទ្ធភាពកំរិតណាដែរ ?

១ / មានប្រសិទ្ធិភាពណាស់ ☐

២ / មានប្រសិទ្ធិភាពមធ្យម ☐

៣/ មានប្រសិទ្ធិភាពតិចតួច ☐

៤/ មិនមានទេ ☐

ហេតុអ្វី?..............................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

៩- តើអ្នកគិតថាអ្នកមានការផ្លាស់ប្តូរដែរឬទេ ចំពោះការអនុវត្តន៍ការងារដែលទាក់ទងទៅនឹងអំពើហិង្សាប្រឆាំងនឹងស្ត្រីនោះ ?

១/មាន ☐

២/ ធម្មតា ☐

៣/ មិនមានទេ ☐

ហេតុអ្វី?.............................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

១០- តើអ្វីដែលនាំឱ្យមានការផ្លាស់ប្តូរនោះ ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

១១- តើអ្នកបានរៀនអ្វីខ្លះ ទាក់ទងនឹងអំពើហិង្សាប្រឆាំងនឹងស្ត្រី ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

១៣- តើអ្វីខ្លះដែលជាប្រភពនៃចំណេះដឹងថ្មីៗរបស់អ្នក ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៤- ចាប់តាំងពីបានចូលរួមវគ្គបណ្តុះបណ្តាលកន្លងមក តើអ្នកមានការខុសប្លែកគ្នាត្រង់ណាខ្លះ នៅពេលដែលមានជនរងគ្រោះជាស្ត្រី ឬ (បុរស ឬ កុមារ) មកជួបអ្នកឱ្យជួយដោះស្រាយ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................

..........................................................................................................................

........................

១៥- តើអ្នកអាចឱ្យជាឧទាហរណ៍មួយអំពីអ្វីដែលបានផ្លាស់ប្តូរនៅក្នុងសហគមន៍របស់អ្នក ដែលជាលទ្ធផលនៃការបណ្តុះបណ្តាល និងសកម្មភាពការងាររបស់អ្នកបានដែរឬទេ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៦- តើមានមនុស្សផ្សេងទៀត ដែលកំពុងចូលរួមក្នុងការបង្រៀនអំពីអំពើហិង្សាប្រឆាំងនឹងស្ត្រីនេះដែរឬទេ ?

១/ មាន ☐

២/ មិនមាន ☐

៣/ មិនដឹង ☐

មានអ្នកណាខ្លះ?.............................................................................................................................

..........................................................................................................................................

..........................................................................................................................................

១៦- តើអ្នកបានបង្កើតបណ្តាញសហគមន៍ ដែលធ្វើការពាក់ពន្ធ័ទៅនឹងអំពើហិង្សាប្រឆាំងនឹងស្ត្រីនេះ ជាមួយអាជ្ញាធរមូលដ្ឋានដ៏ទៃទៀតដែរឬទេ ?

១/ មាន ☐ ជាមួយមូលដ្ឋានណាខ្លះ ? ........................................................................

២/ មិនមាន □ហេតុអ្វី?.....................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

១៧- យោបល់ផ្សេងៗ

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

**សូមអរគុណដល់អ្នកដែលចំណាយពេលវេលា នឹងផ្តល់ព័ត៌មានដល់ក្រុមការងារយើងខ្ញុំ ។**

□□□

# ឧបសម្ព័ន្ធទី៥: ទំរង់វាយតម្លៃសហគមន៍

ថ្ងៃ ខែ ឆ្នាំ:..............................................................................................................

ទីកន្លែង: ..............................................................................................................

ឈ្មោះអ្នកភូមិ:..........................................................................................................

ឈ្មោះអ្នកសម្ភាសន៍:....................................................................................................

I- **ផ្នែកទី ១**

៦. មុខរបរ

១/ កសិករ ☐

២/ កម្មករ ☐

៣/ សិស្សសាលា ☐

៤/ មេផ្ទះ ☐

៥/ មន្ត្រីរាជការ ☐

៧. អាយុ

១/ ១៨ឆ្នាំ- ២៤ ឆ្នាំ ☐

២/ ២៥ឆ្នាំ- ៤0 ឆ្នាំ ☐

៣/ ៤១ឆ្នាំ ឡើង ☐

៨. ស្ថានភាពគ្រួសារ

១ / នៅលីវ ☐

២ / មានគ្រួសារហើយ ☐

៣/ មេម៉ាយ/ពោះម៉ាយ ☐

៩. ភេទ

១ / ស្រី ☐

២/ ប្រុស ☐

១០. ការអប់រំ

១/ ចេះអាន និងសរសេរ ☐

២ / ចេះអានមិនចេះសរសេរ ☐

៣ / ចេះសរសេរ មិនចេះអាន ☐

៤ /មិនចេះអាន និងសរសេរ ☐

II- **ផ្នែកទី២**

៦- តើអ្នកដឹងថាមានបណ្តាញការងារ រឺមានការផ្សព្វផ្សាយពី អំពើហិង្សាប្រឆាំងនឹងស្ត្រីនៅក្នុងភូមិរបស់អ្នកដែរឬទេ ?

១ / បាទ/ចាស ☐

២ / ទេ ☐ (បន្តទៅសំនួរទី ១១ -១៣ និង ១៦)

៧- តើអ្នកធ្លាប់បានចូលរួមជាមួយសកម្មភាពរបស់បណ្តាញ និង ការផ្សព្វផ្សាយដែរឬទេ ?

១ /បាទ/ចាស ☐

២/ ទេ ☐ ហេតុអ្វី?......................................................................................................

៨- តើអ្នកបានដឹងអំពីបណ្តាញការងារ និង ការផ្សព្វផ្សាយពីអំពើហិង្សាប្រឆាំងនឹងស្ត្រីនេះ តាមរយៈអ្វីខ្លះ ?

១ / ដោយសារបានចូលរួមជាមួយសកម្មភាពបណ្តាញរបស់គេ ☐

២/ ដោយបានទទួលការណែនាំពីអជ្ញាធរមូលដ្ឋាន ☐

៣ /ដោយបានស្វែងរកឱ្យគេជួយ ☐

៤/ បានឮពីអ្នកជិតខាង ☐

៩- តើសកម្មភាពរបស់បណ្តាញ ឬការផ្សព្វផ្សាយណាមួយ ដែលអ្នកធ្លាប់បានចូលរួម?

១ / វគ្គអប់រំ ☐

២ / រូបភាពបិទប្រកាស់ ☐

៣/ ការអប់រំក្រៅប្រពន្ធ័ ☐

៤ / ផ្សេងៗ ☐

៥/ មិនដឹង ☐

១០- តើប្រធានបទណាមួយដែលអ្នកចាប់អារម្មណ៍ និងយល់ច្រើនជាងគេបំផុត ?

១ / អំពើហិង្សាក្នុងគ្រួសារ ☐

២/ ការចាប់រំលោភសេពសន្ថវៈ ☐

៣ / ការជួញដូរផ្លូវភេទ ☐

៤ / ច្បាប់ ☐

៥ /ផ្សេងៗ ☐

.....................................................................................................................................................

.....................................................................................................................................................

១១- តើអ្នកគិតថាអាជ្ញាធរដែនដីមានវិធីសាស្ត្រ រឹសកម្មភាពអ្វីទេ ដើម្បីធ្វើឱ្យមានការកាត់បន្ថយអំពើហិង្សាប្រឆាំងនឹងស្ត្រីដែរ រឺទេ នៅក្នុងភូមិរបស់អ្នក?

១/ មាន ☐មានអ្វីខ្លះ ? ..........................................................................

២/ មិនមានទេ ☐

៣/ អត់ដឹង ☐

ហេតុអ្វី?.......................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

១២- តើអ្នកពេញចិត្តក្នុងការស្វែងរកជំនួយពីពួកគាត់ (អាជ្ញាធរមូលដ្ឋាន) ឬទេ នៅពេលអ្នកមានបញ្ហាទាក់ទងទៅនឹងអំពើហិង្សាប្រឆាំងនឹងនារីភេទនោះ ?

១/ ពេញចិត្ត ☐

២/ ធម្មតា ☐

៣/ មិនពេញចិត្ត ☐

ហេតុអ្វី?.......................................................................................................................

.....................................................................................................................................................

.....................................................................................................................................................

១៣. ក្នុងចំណោមចំនុចខាងក្រោមនេះ តើចំនុចណាមួយដែលអាចជួយកាត់បន្ថយអំពើហិង្សាប្រឆាំងនឹងស្ត្រី ? (ចំលើយច្រើនជាង ១)

១/ ការផ្លាស់ប្តូរឥរិយាបថ ☐

២ / រាយការណ៍ភ្លាមៗទៅដល់អជ្ញាធរមូលដ្ឋានដែលនៅជិតបំផុតដើម្បីឱ្យជួយ ☐

៣ / យល់ពីគ្នាទៅវិញទៅមករវាងប្តីនឹងប្រពន្ធ ☐

៤ / មិនដឹង ☐

១៤- តើគំរោងដែលកំពុងធ្វើការកាត់បន្ថយអំពើហិង្សានៅក្នុងសហគមន៍របស់អ្នកទទួលបានលទ្ធផលកម្រិតណារហូតមកទល់ពេលនេះ?

១ /បានច្រើន ☐

២/ បានមធ្យម ☐

៣/បានតិច ☐

៤/អត់បានសោះ ☐ ហេតុអ្វី ? (បញ្ជាក់សំនួរ)

ហេតុអ្វី?......................................................................................................................................

..................................................................................................................................................

..............................................................................................................................................

១៥- ចូរអ្នកពន្យល់ ឬលើកជាឧទាហរណ៍ អំពីអ្វីដែលបានផ្លាស់ប្តូរនៅក្នុងសហគមន៍របស់អ្នកដែលជាលទ្ធផលនៃគំរោងនេះ?

..................................................................................................................................................

..................................................................................................................................................

..............................................................................................................................................

១៦- យោបល់ផ្សេងៗ

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

**សូមអរគុណដល់អ្នកដែលចំណាយពេលវេលា នឹងផ្តល់ព័ត៌មានដល់ក្រុមការងារយើងខ្ញុំ ។**

☐☐☐